ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២៧ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២_១_១៩៩៥ _ព្រះរាជក្រឹត្យ លេខ ជស.រកត ០១៩៥/០១ ១២០៣

២៥_៧_១៩៩៥ _ព្រះរាជក្រឹត្យ លេខ ជស.រកត ០៧៩៥/០១ ១២០៤

២៥_៧_១៩៩៥ _ព្រះរាជក្រឹត្យលេខ ជស.រកត ០៧៩៥/០២ ១២០៥

II-ទីស្តីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

២៥_៧_១៩៩៥ _អនុក្រឹត្យ លេខ ៥៨ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីដែលមិនបានប្រើប្រាស់ ១២០៧

២៦_៧_១៩៩៥ _អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីប្រាក់បំណាច់សំរាប់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ និងទីប្រឹក្សា ១២០៩

២៤_៧_១៩៩៥ _អនុក្រឹត្យលេខ ៨៤ អនក្រ. ស្តីពីការផ្លាស់ប្តូរតំណែងមន្ត្រីរាជការផ្នែកនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ១២១១

២៦_៧_១៩៩៥ _អនុក្រឹត្យលេខ ៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២១១

៣១_៧_១៩៩៥ _អនុក្រឹត្យ លេខ ៦០ អនក្រ.ប្រក ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ១២១២

៣១_៧_១៩៩៥ _អនុក្រឹត្យ លេខ ៦១ អនក្រ.បក ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ១២២២

៣១_៧_១៩៩៥ _អនុក្រឹត្យ លេខ ៦២ អនក្រ.បក ស្ដីពីការគ្រប់គ្រងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ ១២២៤

២_សេចក្ដីសំរេច

២៥_៧_១៩៩៥ _សេចក្ដីសំរេច លេខ ៥៣ សសរ ស្ដីពីបង្កើតគណៈកម្មការត្រួតពិនិត្យគោលនយោបាយចំពោះជនពលិពិការ ១២២៧

២៧_៧_១៩៩៥ _សេចក្ដីសំរេច លេខ ៥៤ សសរ ស្ដីពីការបង្កើតគណៈកម្មការផ្ទួសផ្ទុលព្រលានយន្តហោះ ខេត្តរតនគិរី ១២៣០

២៩_៧_១៩៩៥ _សេចក្ដីសំរេច លេខ ៥៥ សសរ ស្ដីពីការបង្កើតលេខាធិការ ដ្ឋាននៃក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ «ក.ក.ជ» ១២៣២

III-ការងារបណ្ដាក្រសួង

១_សេចក្ដីប្រកាសអន្តរក្រសួង

២៤_៧_១៩៩៥ _ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ លេខ ០២ ប្រ.ក ស្ដីពីសមត្ថកិច្ច នៃការផ្ដល់ទិដ្ឋាការចូល–ចេញ និងស្នាក់នៅ ព្រះរាជាណាចក្រកម្ពុជា ១២៣៥

២_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សេចក្ដីសំរេច

២៧_៧_១៩៩៥ _សេចក្ដីសំរេច លេខ ៤១៩ សសរ.កសរក ស្ដីពីការតែងតាំងគណៈកម្មការដេញថ្លៃជីគីមី ក្នុងក្របខ័ណ្ឌជំនួយរបស់ FAO ១២៣៧

៣១_៧_១៩៩៥ _ប្រកាសលេខ ៤៣២ ប្រកកសក ស្តីពីការបង្កើតរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅ នៃការិយាល័យរបស់នាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និងផ្សព្វ ១២៣៩

៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

២៦_៧_១៩៩៥ _ប្រកាស លេខ ៥៣៦ ផក.ប្រក អនុញ្ញាតអោយលោក ជាង សំអាត ជនជាតិខ្មែរ បើកដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម ១២៤២

២៦_៧_១៩៩៥ _ប្រកាស លេខ ៥៣៧ ផក.ប្រក. អនុញ្ញាតអោយលោក លើ អេងហុង ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មកែច្នៃផ្តៅ ១២៤៣

២៦_៧_១៩៩៥ _ប្រកាស លេខ ៥៤០ បល.ប្រក ស្តីពីការផាកព្យួតរោងចក្រឡផ្ទជ្រោយអំពិល ស្ថិតនៅភូមិលេខ ១ ឃុំក្បាលកោះ ស្រុកគៀនស្វាយ ខេត្តកណ្តាល ១២៤៤

២៧_៧_១៩៩៥ _ប្រកាស លេខ ៥៤១ ផក.ប្រក អនុញ្ញាតអោយ ឃីន តង ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតផាល ឆ្នាំង និង ខ្ទះ ១២៤៥

២៧_៧_១៩៩៥ _ប្រកាស លេខ ៥៤២ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ខែម ណាត ជនជាតិខ្មែរ បន្តដំណើរការផលិតឡផ្ទ និងគ្រឿង ១២៤៥

២៧_៧_១៩៩៥ _ប្រកាស លេខ ៥៤៣ ផក.ប្រក អនុញ្ញាតអោយលោក យង់ ស្រ្វយ ជនជាតិខ្មែរ ជាម្ចាសរោងម៉ាស៊ីនកិនស្រូវ ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក ហាន់ ពេភ វិញ ១២៤៦

២៧_៧_១៩៩៥ _ប្រកាស លេខ ៥៤៤ ផក.ប្រក អនុញ្ញាតអោយលោក អេង ស្រ៊ុន ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ១២៤៦

២៧_៧_១៩៩៥ _ប្រកាស លេខ ៥៤៥ ផក.ប្រក អនុញ្ញាតអោយលោក លាង ត្រី ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតទឹកត្រីពិសេស យីហោ «អៀងត្រី» ១២៤៧

៣១_៧_១៩៩៥ _ប្រកាស លេខ ៥៥១ បល.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការ ១២៤៧

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

២៤_៧_១៩៩៥ _ប្រកាស លេខ ១៥៧/៩៥ ពម.ប្រក ស្តីពីការអនុញ្ញាតអោយ លោក តាំង សុភាព បើកអាជីវកម្មរោងពុម្ព ដែលមានឈ្មោះ «ពន្លឺពេជ្រ» ១២៤៨

២៤_៧_១៩៩៥ _ប្រកាស លេខ ១៥៨/៩៥ ពម.ប្រក ស្តីពីការអនុញ្ញាតអោយ សារពត៌មាន «ខ្មែរអង្គរ» ចេញផ្សាយ ដោយមានលោក សាយ យាង ជាចាងហ្វាងការផ្សាយ ១២៥០

២៦_៧_១៩៩៥ _សេចក្តីសំរេច លេខ ១៥៩/ ពមស.ស.រ ស្តីពីការបង្កើត គណៈកម្មការសាងសង់ ១២៥១

២៨_៧_១៩៩៥ _ប្រកាស លេខ ១៦០/ពម.ប្រក ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ របស់មន្ត្រីរាជការ ១២៥២

២៨_៧_១៩៩៥ _ប្រកាស លេខ ១៦១/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រី រាជការ ១២៥៣

៣១_៧_១៩៩៥ _ប្រកាស លេខ ១៦៣/៩៥ ពម.ប្រក ស្តីពីការផ្លាស់ប្តូរកន្លែង ធ្វើការរបស់មន្ត្រីរាជការ ១២៥៤

៣១_៧_១៩៩៥ _ប្រកាស លេខ ១៦៤/៩៥ ពម.ប្រក ស្តីពីការលុយឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង ១២៥៥

៥_នីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

២៤_៧_១៩៩៥ _ប្រកាស លេខ ១៣៣ ប្រក.វវស.បុ ស្តីពីការបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវវិស័យបេតិកភ័ណ្ឌវប្បធម៌ ១២៥៦

[illegible]_៧_១៩៩៥ _ប្រកាស លេខ ១៣៥ ប្រក.វវស.បុ ស្តីពីការបង្កើតគណៈកម្មការមេប្រយោគប្រឡងជ្រើសរើស សិស្ស និស្សិត ចូលរៀនឆ្នាំសិក្សា ១៩៩៥–៩៦ ១២៥៧

២៥_៧_១៩៩៥ _ប្រកាស លេខ ១៣៦ ប្រក.វវស.បុ ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ១២៥៩

២៦_៧_១៩៩៥ _ប្រកាស លេខ ១៣៧ ប្រក.វវស.បុ ស្តីពីការបង្កើតគណៈកម្មការពិនិត្យ និងវាយតម្លៃរបាយការណ៍បញ្ចប់កម្មសិក្សារបស់និស្សិតឆ្នាំទី ៥ ជំនាន់ទី ១នៃមហាវិទ្យាល័យស្ថាបត្យកម្ម និងនគររោបនីយវិទ្យាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ១២៦០

៣១_៧_១៩៩៥ _ប្រកាស លេខ ១៣៨ ប្រក.វវស.បុ ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយ មានជ័យ ១២៦១

៣១_៧_១៩៩៥ _ប្រកាស លេខ ១៣៩ ប្រក.វវស.បុ ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ១២៦៣

៣១_៧_១៩៩៥ _ប្រកាស លេខ ១៤០ ប្រក.វវស.បុ ស្តីពីការផ្អាកការងារមួយរយៈដោយពុំទទួលបៀវត្ស ១២៦៣

៣១_៧_១៩៩៥ _ប្រកាស លេខ ១៤១ ប្រក.វវស.បុ ស្តីពីការផ្អាកការងារមួយរយៈដោយពុំទទួលបៀវត្ស ១២៦៥

៣១_៧_១៩៩៥ _ប្រកាស លេខ ១៤២ ប្រក.វវស.បុ ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបាត់ដំបង ១២៦៦

៦_ទីស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ប្រកាស

២៦_៧_១៩៩៥ _ប្រកាស លេខ ៣១៥ សកប ស្តីពីការតែងតាំង និងតម្លើងឋានៈមន្ត្រីរាជការ ១២៦៧

៧_ទីស្តីការ ក្រសួងធម្មការ និងសាសនា

ប្រកាស

២៧_៧_១៩៩៥ _ប្រកាស លេខ ១៥៤/៩៥ កធស.ប្រក ស្តីពីការទទួលស្គាល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួង ១២៦៨

៣១_៧_១៩៩៥ _ប្រកាស លេខ ១៥៩/៩៥ កធស ស្តីពីការបែងចែកភារកិច្ចជូនដល់រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា និងទីប្រឹក្សា ១២៦៩

៣១_៧_១៩៩៥ _ប្រកាស លេខ ១៦០/៩៥ កធស ស្តីពីការទទួលស្គាល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងធម្មការ និងសាសនា ១២៧១

៨_ទីស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

២៥_៧_១៩៩៥ _ប្រកាស លេខ ១៣៧៤ ប្រក.បស្ថ ស្តីពីការផ្ទេរភារកិច្ចមន្ត្រី ១២៧២

៣៧_៧_១៩៩៥ _ប្រកាស លេខ ១៣៨៩ ប្រក.បស្ស ស្ដីពីការតែងតាំងមន្ត្រី រាជការ ១២៧៣

រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

សេចក្ដីសំរេច

២៧_៨_១៩៩៥ _សេចក្ដីសំរេច លេខ ៥២៨ សសរ.មស.ប្រក ស្ដីពីការបែងចែក សិស្ស និស្សិត ចំនួន ៦ នាក់ ដែលទើបបញ្ចប់ការសិក្សា នៅក្រៅប្រទេស ១២៧៤

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភាស្តីពីការជ្រើសតាំងសម្តេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា នាសម័យប្រជុំពេញអង្គលើកទី ១ និតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភា ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៤

ត្រាស់បង្គាប់

មាត្រា ១ តែងតាំង ឥស្សរជន ដូចមានរាយនាមខាងក្រោមនេះ ជាឧត្តមទីប្រឹក្សាផ្ទាល់ និងជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា :

- ឯកឧត្តម **ឃឹម នៃឈី** ជាឧត្តមទីប្រឹក្សាផ្ទាល់ មានឋានៈស្មើនឹងរដ្ឋមន្ត្រីទទួលបន្ទុកជួយប្រធានរដ្ឋសភា ក្នុងការដឹកនាំក្រុមឧត្តមទីប្រឹក្សា និងទីប្រឹក្សាផ្ទាល់ ។
- ឯកឧត្តម **អ៊ុំ សារិទ្ធ** ជាទីប្រឹក្សាផ្ទាល់ មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ ទទួលបន្ទុកជានាយកខុទ្ទកាល័យរបស់ប្រធានរដ្ឋសភា។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២ ខែ មករា ឆ្នាំ ១៩៩៥

កចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

ព្រះរាជក្រឹត្យលេខ ជស/រកត/០៧៩៥/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នរាជាភូមិ

រាជហរិវង្ស ឧបតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភាស្តីពីការជ្រើសតាំងសម្តេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា នាសម័យប្រជុំពេញអង្គលើកទី ១ និតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភា ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង ឥស្សរជន ដូចមាននាមខាងក្រោមនេះ ជាឧត្តមទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមាន ឋានៈស្មើនឹងរដ្ឋលេខាធិការ :

- ឯកឧត្តម **ស៊ឹម កា** ទទួលបន្ទុកទំនាក់ទំនងសាធារណៈ និងកិច្ចការទីក្រុងភ្នំពេញ។
- ឯកឧត្តម **ឃួន ឈឿ** ទទួលបន្ទុកកិច្ចការការពារជាតិ និងសន្តិសុខ ។
- ឯកឧត្តម **ឃាស់ សុខ** ទទួលបន្ទុកកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។
- លោកជំទាវ **ផ្លែក ភិរុណ** ទទួលបន្ទុកកិច្ចការមនុស្សធម៌ និងសង្គមកិច្ច ។
- ឯកឧត្តម **តាំង សារីម** ទទួលបន្ទុកកិច្ចការពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ។

_ឯកឧត្តម ខាត់ សារិន ទទួលបន្ទុកកិច្ចការតុលាការ និងដោះស្រាយពាក្យបណ្តឹងរបស់ប្រជារាស្ត្រ

_ឯកឧត្តម ឈាវ សុខ ទទួលបន្ទុកកិច្ចការកសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

ព្រះរាជក្រឹត្យលេខ ជស/រកត/០៧៩៥/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

_ យោងតាមសេចក្តីសំរេចរបស់រដ្ឋសភាស្តីពីការជ្រើសតាំងសម្តេច ជា ស៊ីម ជាប្រធានរដ្ឋសភា នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣

_ យោងតាមសំណើរបស់ប្រធានរដ្ឋសភា ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៩៥

សម្រេចបញ្ជាថា

មាត្រា ១ : តែងតាំង ឥស្សរជន ដូចមានរាយនាមខាងក្រោមនេះ ជាទីប្រឹក្សា ផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ :

- ឯកឧត្តម **ជ័យ សារ៉ុន** ទទួលបន្ទុកកិច្ចការស្រាវជ្រាវ និងបូកសរុប ។
- ឯកឧត្តម **ថុង ចន់** ទទួលបន្ទុកកិច្ចការមហាផ្ទៃ អង្កេត និងដោះសារអាត។
- ឯកឧត្តម **សុខ ឥសាន្ត** ទទួលបន្ទុកកិច្ចការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ និងថាមពល ។
- លោកជំទាវ **មាន សំអាន** ទទួលបន្ទុកកិច្ចការនារី សមាគម និងអង្គការសង្គម ។
- ឯកឧត្តម **អ៊ុំ សារិទ្ធ** ទទួលបន្ទុកកិច្ចការមុខងារសាធារណៈ ។
- ឯកឧត្តម **ប៉ែន ស៊ីម៉ន** ទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច ។
- ឯកឧត្តម **ជ័យ សោភា** ទទួលបន្ទុកកិច្ចការវប្បធម៌ អប់រំ និងវិចិត្រសិល្បៈ ។
- ឯកឧត្តម **ទង់ សុទ្រា** ទទួលបន្ទុកកិច្ចការទំនាក់ទំនងជាមួយមហាជន ។
- ឯកឧត្តម **ទេព ខុន** ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ជនបទ ។
- ឯកឧត្តម **ហែម សាមិន** ទទួលបន្ទុកកិច្ចការទំនាក់ទំនងជាមួយមូលដ្ឋាន ។
- លោកជំទាវ **ជ័យ កញ្ញា** ទទួលបន្ទុកកិច្ចការសុខាភិបាល និងសង្គមកិច្ច ។
- ឯកឧត្តម **ម៉ុន សំ** ទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ និងធនាគារ ។
- ឯកឧត្តម **ចាន់ សារុន** ទទួលបន្ទុកកិច្ចការផលិតកម្មស្រូវ ធនធានទឹក និងការដាំដើមឈើឡើងវិញ ។
- ឯកឧត្តម **នឹម ធុត** ទទួលបន្ទុកកិច្ចការរៀបចំអគារ និងពិមាន ។
- ឯកឧត្តម **អ៊ុក ប្រាថ្នា** ទទួលបន្ទុកកិច្ចការយុវជន និងកីឡា ។
- ឯកឧត្តម **អ៊ុំ ញៀវញ៉ូ** ទទួលបន្ទុកកិច្ចការទំនាក់ទំនង ជាមួយគណបក្សនយោបាយនានា ។
- ឯកឧត្តម **ម៉ុក យុទ្ធា** ទទួលបន្ទុកកិច្ចការផែនការ វិនិយោគ ទេសចរណ៍ ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅ

រដ្ឋាភិបាល ។

- ឯកឧត្តម ឆាំង សុខ ទទួលបន្ទុកកិច្ចការសារពត៌មាន និងនយោបាយសាធារណៈ
- ឯកឧត្តម អ៊ុង ឆី ទទួលបន្ទុកច្បាប់ និងកិច្ចការរបស់រដ្ឋសភា ។
- ឯកឧត្តម ស៊ួស ការណាន់ ទទួលបន្ទុកកិច្ចការជនជាតិ និងធម្មការ ។
- ឯកឧត្តម សយ ស៊ីផុន ទទួលបន្ទុកកិច្ចការសហជីព និងអង្គការសង្គម ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច . ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ជា ស៊ីម

II-ឯកសារគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៨ អ.ន.ក្រ

ស្ដីពី

ការបង្កើតគណៈកម្មការអោយតំលៃដីមិនបានប្រើប្រាស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាស
អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
–បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ
១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
–បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយ
ប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
–តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សម្រេច

មាត្រា ១ : បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
ដែលមានសមាសភាពដូចខាងក្រោម :

–រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង	ជាប្រធាន
–ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ឬអ្នក តំណាង	ជាអនុប្រធាន
–ប្រធាននាយកដ្ឋានពន្ធដារ ឬអ្នកតំណាង	ជាសមាជិក
–ប្រធាននាយកដ្ឋានទ្រព្យរដ្ឋ ឬអ្នកតំណាង	ជាសមាជិក
–ប្រធាននាយកដ្ឋានសុរិយោដី ឬអ្នកតំណាង	ជាសមាជិក

មាត្រា ២ : គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

–បង្កើតបញ្ជីរាយឈ្មោះទីក្រុង និងតំបន់ដែលមានដីត្រូវជាប់ពន្ធ
–កំណត់ប្រចាំឆ្នាំនូវតំលៃដីក្នុងមួយម៉ែត្រក្រឡា
–ផ្តល់មតិចំពោះរឿងវិវាទ

មាត្រា ៣ : គណៈកម្មការនេះមានសិទ្ធិចាត់តាំងអនុគណៈកម្មការនៅតាមខេត្តក្រុងនិមួយៗ សំ-
រាប់ជំនួយការក្នុងការអនុវត្តន៍ភារកិច្ចខាងលើ ។

មាត្រា ៤ : គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួង
សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ
វត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ និងអស់
លោកដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ

ឡាយព្រះហស្តលេខា និងចុះហត្ថលេខាដោយ

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥៩ អនក្រ.បក

ស្តីពីប្រាក់បំណាច់សំរាប់សមាជិករាជរដ្ឋាភិបាល

អនុរដ្ឋលេខាធិការ និងទីប្រឹក្សា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៅតាមក្រសួងស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងសេចក្តីសំរេចរបស់អង្គប្រជុំពេញគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : ផ្តល់ប្រាក់បំណាច់បន្ថែមលើសបៀវត្សប្រចាំខែ ជូនសមាជិករាជរដ្ឋាភិបាល ដែលមិនមែនជាសមាជិកសភា គឺ អនុរដ្ឋលេខាធិការ នៃក្រសួង រដ្ឋលេខាធិការដ្ឋាន ទីប្រឹក្សា

នៃរាជរដ្ឋាភិបាល ទីប្រឹក្សាសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និងទីប្រឹក្សាសម្តេច នាយករដ្ឋមន្ត្រីទី ២ ដូចតទៅ ÷

- ប្រាក់បំណាច់ តំណាង
- ប្រាក់បំណាច់ បដិសណ្ឋារកិច្ច
- ប្រាក់បំណាច់ បេសកកម្ម
- ប្រាក់ ឈ្នួលផ្ទះ ទឹក ភ្លើង

មាត្រា ២ : ប្រាក់បំណាច់លើបៀវត្សប្រចាំខែ ត្រូវបានកំណត់ក្នុងតារាងដូចខាងក្រោម ÷

ប្រភេទប្រាក់បំណាច់ មុខតំណែង	ប្រាក់បំណាច់ តំណាង	ប្រាក់បំណាច់ បដិសណ្ឋារកិច្ច	ប្រាក់បំណាច់ បេសកកម្ម	ប្រាក់ឈ្នួល ផ្ទះ ទឹក ភ្លើង	សរុប
នាយករដ្ឋមន្ត្រី	១.១៣៧.៥០០៛	៩៦២.៥០០៛	៦១២.៥០០៛	៩៦២.៥០០៛	៣.៦៧៥.០០០៛
ឧបនាយករដ្ឋមន្ត្រី	៩១៨.៧៥០៛	៧៤៣.៧៥០៛	៤៨១.២៥០៛	៦៥៦.២៥០៛	២.៨០០.០០០៛
ទេសរដ្ឋមន្ត្រី	៨៣១.២៥០៛	៦៥៦.២៥០៛	៣៩៣.៧៥០៛	៥៦៨.៧៥០៛	[illegible]
រដ្ឋមន្ត្រី	៧៤៣.៧៥០៛	៥៦៨.៧៥០៛	៣០៦.២៥០៛	៤៨១.២៥០៛	២.១០០.០០០៛
រដ្ឋលេខាធិការ	៧០០.០០០៛	៤៨១.២៥០៛	២៦២.៥០០៛	៣០៦.២៥០៛	១.៧៥០.[illegible]
អនុរដ្ឋលេខាធិការ	៥២៥.០០០៛	៣៥០.០០០៛	២៦២.៥០០៛	២៦២.៥០០៛	១.៤០០.[illegible]

មាត្រា ៣ : ចំពោះសមាជិករាជរដ្ឋាភិបាល ដែលមិនមែនជាសមាជិកសភា អនុរដ្ឋលេខាធិការ ទីប្រឹក្សាដូចកំណត់ក្នុងមាត្រា ១ ដែលមានតំណែងពីរ ឬបីមានសិទ្ធិទទួលប្រាក់បំណាច់ខាងលើបានតែមួយមុខតំណែង ក្នុងតំណែងណាមួយក៏បាន ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៨៤ អ.ន.ក្រ

ស្តីពីការផ្លាស់ប្តូរតំណែងមន្ត្រីរាជការ

ផ្នែកនគរបាលជាតិ នៃក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- យោងសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉េង ម៉ារ៉ាឌី** បច្ចុប្បន្នអគ្គាធិការកិច្ចការនយោបាយ រដ្ឋបាលនិងនគរបាលជាអគ្គនាយករងទី១ នគរបាលជាតិ ក្រសួងមហាផ្ទៃជំនួស លោក **ខួន សឿរ** ដែលត្រូវផ្លាស់ចេញ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងអស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៨៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងងារស្ថាបនាជាតិ
- តាមសំណើរបស់ក្រសួងសុខាភិបាល

សំរេច

មាត្រា ១ . ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះក្រុមហ៊ុន T.T.H.K CO .LTD ដែលបានផ្តល់នូវរថយន្តពិលានសង្គ្រោះ ម៉ាកតូយ៉ូតា Hi. Acc ចំនួន ១ គ្រឿង តម្លៃ ២៩.០០០ ដុល្លារអាមេរិក ចំពោះក្រសួងសុខាភិបាល ។

មាត្រា ២ : សមាជរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦០ អនក្រ.បក

ស្តីពីការគ្រប់គ្រងលក្ខន្តិកៈមន្ត្រីសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- យោងព្រះរាជក្រឹត្យលេខ សន/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស-៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

បញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះមានគោលបំណង [illegible] និងបទបញ្ញត្តិទាំងឡាយ ដើម្បីគ្រប់គ្រងលទ្ធកម្ម [illegible] នៅព្រះរាជាណាចក្រកម្ពុជា [illegible] គោលដៅ នៃការ [illegible] ប្រើប្រាស់ត្រឹមត្រូវ ភាពទៀងទាត់ និងភាពតែមួយ [illegible] ការសន្សំសំចៃ និងមានប្រសិទ្ធភាព [illegible] ការលោតលង់ និងជ្រើសរើសទិញប្រើ [illegible]

មាត្រា ២ : ការអនុវត្ត [illegible] នៃអនុក្រឹត្យនេះ ត្រូវធ្វើឡើងអោយបានសមស្របទៅនឹងលក្ខខណ្ឌ [illegible] និងបទបញ្ញត្តិស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ (Implementing Rules and Regulations Governing Public Procurement-IRR PP) និងសេចក្តីណែនាំទាំងឡាយ [illegible] បញ្ញាដទៃទៀតស្របគ្នាដែលចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣ : អនុក្រឹត្យនេះ [illegible] និងបទបញ្ញត្តិស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ដែល [illegible] រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តដោយអង្គភាពសាធារណៈ [illegible] ឬមូលដ្ឋានរួមទាំងស្ថាប័ន ដែលរដ្ឋកាន់កាប់ ឬស្វយ័តគ្រប់គ្រង

ចំពោះរាល់ទង្វើលទ្ធកម្ម ទំនិញ សេវា កិច្ចសន្យាការងារសាងសង់ និងការជ្រើសរើសទីប្រឹក្សា ។

ជំពូក I

វិធីសាស្ត្រ និងនីតិវិធី នៃលទ្ធកម្ម

ផ្នែកទី ១

វិធីសាស្ត្រ

មាត្រា ៤ : លទ្ធកម្ម ទំនិញ សេវា ឬកិច្ចសន្យាសាងសង់ ធ្វើឡើងដោយអង្គការសាធារណៈ ត្រូវអនុវត្តតាមរបៀប ២ យ៉ាងគឺ :

១_ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ ។

២_វិធីផ្សេងទៀត ដែលមិនមែនជាការដេញថ្លៃ ដោយប្រកួតប្រជែងជាចំហ ។

មាត្រា ៥ : ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ ត្រូវបានយកមកប្រើនៅពេលដែលមានអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការច្រើនគ្រប់គ្រាន់ ដែលអាចផ្តល់ទំនិញ សេវា ឬការងារដែលចង់បាន ។ ការងារនេះ នឹងផ្តល់ជាអត្ថប្រយោជន៍ដល់រាជរដ្ឋាភិបាល ប្រសិនបើការប្រកួតប្រជែង និងនាំទៅដល់ការជ្រើសរើសអ្នកផ្គត់ផ្គង់ និងអ្នកទទួលការណាមួយដែលផ្តល់នូវសំណើ ដែលមានលក្ខណៈសន្សំសំចៃ និងអត្ថប្រយោជន៍ជាងគេនោះ ។

មាត្រា ៦ : ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ អាចធ្វើឡើងជាលក្ខណៈអន្តរជាតិ ដែលគេអោយឈ្មោះថា ការដេញថ្លៃដោយប្រកួតប្រជែងជាអន្តរជាតិ (International Competitive Bidding-ICB) ឬមួយក៏ត្រឹមតែក្របខ័ណ្ឌក្នុងស្រុក ដែលគេអោយឈ្មោះថា ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក (Domestic Competitive Bidding-DCB) ។ គេប្រើ ICB សំរាប់កិច្ចសន្យាដែលមានតំលៃធំ ហើយមានការចូលរួមពីអ្នកដេញថ្លៃបរទេស និងអាចផ្តល់នូវលទ្ធភាពទូលំទូលាយក្នុងការជ្រើសរើសយកសំណើដែលល្អបំផុត ។ ផ្ទុយទៅវិញ DCBត្រូវបានគេអនុវត្តនៅក្នុងករណីដែលមានផលិតកម្មក្នុងស្រុកគ្រប់គ្រាន់ ឬក៏សមត្ថភាពសាងសង់គ្រប់គ្រាន់ ហើយទំហំទឹកប្រាក់ នៃកិច្ចសន្យាក៏មិនសូវជាធំនឹងអាចទាក់ទាញអារម្មណ៍ដល់អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការបរទេស ។

មាត្រា ៧ : វិធីសាស្ត្រផ្សេងទៀត នៃលទ្ធកម្ម ដែលមិនពាក់ព័ន្ធទៅនឹងការដេញថ្លៃដោយប្រកួត

ប្រជែងជាចំហរនោះមាន ÷

(១)_ពិគ្រោះថ្លៃជាអន្តរជាតិ (២)_ការស្ទង់តម្លៃក្នុងស្រុក (៣)_ការទិញ ឬចុះកិច្ចសន្យាដោយផ្ទាល់ ។ ការពិគ្រោះថ្លៃជាអន្តរជាតិ (International Shopping -IS) ត្រូវអោយមានតារាងតំម្លៃចំនួនបី ពីប្រទេសចំនួន ២ យ៉ាងតិច ។ វិធីនេះត្រូវបានប្រើនៅពេល ដែលទំហំទឹកប្រាក់ នៃកិច្ចសន្យាមិនសូវជាធំ នឹងអាចទាក់ទាញអោយមានការប្រកួតប្រជែងជាអន្តរជាតិទូលំទូលាយ ឬមួយក៏នៅ ពេលដែលចំនួនអ្នកផ្គត់ផ្គង់ ដែលអាចធ្វើការងារនេះបានមានកំរិតតិចតួច ហើយសេចក្តីត្រូវការមានលក្ខណៈបន្ទាន់ និងពេលវេលាមានតិចតួចសំរាប់ប្រើវិធី ICB។ ការស្ទង់តម្លៃក្នុងស្រុក (Domestic Canvassing-DC) គឺត្រូវអោយមានតារាងតំលៃចំនួនបីយ៉ាងតិច ពីអ្នកផ្គត់ផ្គង់ក្នុងស្រុក ។ វិធីនេះត្រូវបានប្រើក្នុងកិច្ចសន្យាផ្គត់ផ្គង់ ដែលទិញផ្ទាល់ពីហាង នូវរាល់វត្ថុ សំភារៈ ឬគ្រឿងផ្គត់ផ្គង់ គ្រឿងបន្លាស់ ឬមួយជាគ្រឿងម៉ាស៊ីនតូចតាច និងបរិក្ខារដែលអាចផ្តល់ដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក ឬតាមតំណាងនៅតាមមូលដ្ឋាន ឬមួយក៏ភ្នាក់ងារទទួលសិទ្ធិ នៃអ្នកផ្គត់ផ្គង់បរទេស។ ការទិញផ្ទាល់ (Direct Purchase-DP) ឬចុះកិច្ចសន្យាផ្ទាល់ (Direct Contracting-DCO) គឺវិធីធ្វើការទាក់ទង ឬចរចាផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការណ៍មួយ ហើយត្រូវអនុវត្តក្នុងកាលៈទេសៈណាមួយដូចខាងក្រោមនេះ ÷

១_វត្ថុដែលត្រូវទិញជាតម្រូវការក្នុងការពង្រីក ឬផ្គួសផុលឧបករណ៍ដែលមានរួចមកហើយ ។

២_ជាឧបករណ៍ដែលអាចផ្តល់បាន តែពីអ្នកផ្គត់ផ្គង់មួយប៉ុណ្ណោះ ។

៣_ជាទំនិញ សេវា ឬការងារដែលត្រូវការជាបន្ទាន់ ដើម្បីទប់ទល់នឹងស្ថានភាព អាសន្ន។

៤_ជាកិច្ចការដែលត្រូវធ្វើពីមុន ឬកំពុងតែធ្វើ ហើយត្រូវពន្យាពេលដោយកត្តាធម្មជាតិ ។

៥_នៅពេលណាមានបញ្ជាទិញថ្មីដែលមួយទៀត នូវមុខទំនិញដែលបានដេញថ្លៃ ពីមុនរួចហើយ តាមការដេញថ្លៃដោយប្រកួតប្រជែង ហើយអាចនឹងគ្មានតំលៃណាទាបជាងនេះទៀតទេ ទោះបីតាមរយៈការដេញថ្លៃណាផ្សេងទៀតក៏ដោយ ។

៦_ការប្រកួតប្រជែងដេញថ្លៃត្រូវខកខាន យ៉ាងហោចណាស់ពីរដងរួចមកហើយ ដោយមូលហេតុមកពីខ្វះអ្នកចូលរួមដេញថ្លៃ ឬពុំមានការឆ្លើយតបក្នុងការដេញថ្លៃ ។

៧_ការទិញទំនិញ ពីស្ថាប័នរបស់រដ្ឋមួយផ្សេងទៀត ឬការងារសាងសង់ដែលស្ថាប័ន រដ្ឋជាអ្នកទទួលបន្ទុក និងប្រើប្រាស់នូវមធ្យោបាយផ្ទាល់ ។

មាត្រា ៨ : ការវាយតំលៃខ្ពស់ ឬទាបលើកិច្ចសន្យា ដែលត្រូវទុកជាមូលដ្ឋាន នៃការជ្រើសរើស តាមវិធីសាស្ត្រ នៃលទ្ធកម្មដូចបានរៀបរាប់ខាងលើ និងមានចែងក្នុងវិធាន និងបទបញ្ញត្តិស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ (IRRPP)។ កំរិតកំណត់ នៃការវាយតំលៃ អាចកែសំរួលបានទៅតាមការសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ផ្នែកទី ២

នីតិវិធី

មាត្រា ៩ : កិច្ចការត្រៀម :

មុននឹងចាប់ផ្តើមធ្វើសកម្មភាពលទ្ធកម្មណាមួយ រាល់នីតិវិធីផ្ទៃក្នុងចាំបាច់ទាំងអស់ ត្រូវតែបានបំពេញគ្រប់គ្រាន់ ។

ដូចជាសេចក្តីត្រូវការនូវទំនិញ សេវា ឬការងារ ត្រូវតែរៀបចំឡើងដោយបញ្ជាក់ ច្បាស់អំពីប្រភពដែលផ្តល់ហិរញ្ញប្បទាន អាជ្ញាធរដែលត្រូវចុះកិច្ចសន្យា ឬជាអ្នកទិញ វិធីលទ្ធកម្មដែលត្រូវកំណត់យក និងសេចក្តីបញ្ជាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៕

មាត្រា ១០ : នីតិវិធី នៃលទ្ធកម្មដោយប្រកួតប្រជែងជាចំហ :

លទ្ធកម្មតាមរយៈការដេញថ្លៃដោយប្រកួតប្រជែងជាចំហ (ICB និង DCB) ត្រូវតែ អនុវត្តទៅតាមនីតិវិធីសំខាន់ៗមួយចំនួន ដើម្បីធានានូវការប្រកួតប្រជែងដែល យុត្តិធម៌ ស្មើភាព និងមានសណ្តាប់ធ្នាប់ ។ នីតិវិធីទាំងនេះ ទំងមានចែងនៅ ក្នុងវិធាន និងបទបញ្ញត្តិស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ (IRRPP) ។ ម្យ៉ាង ទៀតសំរាប់កិច្ចសន្យាសាងសង់ធំៗ ការកំណត់បុរេលក្ខណៈសម្បត្តិ នៃអ្នកទទួល ការ ដែលនឹងចូលរួមដេញថ្លៃត្រូវតែបានធ្វើឡើងមុនពេលចេញ លិខិតអញ្ជើញអោយចូលរួមដេញថ្លៃ ។

មាត្រា ១១ : នីតិវិធីដែលមិនមែនជាការដេញថ្លៃដោយប្រកួតប្រជែង :

នីតិវិធី ដែលត្រូវប្រតិបត្តិតាមវិធីសាស្ត្រលទ្ធកម្មផ្សេងទៀតដូចជា ការពិគ្រោះ តំលៃជាអន្តរជាតិ (IS)-ការស្ទង់តំលៃក្នុងស្រុក (LS) និងការទិញផ្ទាល់ (DP) ៖

ការចុះកិច្ចសន្យាផ្ទាល់ (DCO) ដែលសាមញ្ញ និងផ្ទាល់ជាង ពីព្រោះគ្មានការប្រកួតប្រជែង ។ នីតិវិធីនេះ ក៏មានចែងក្នុង IRRPP ។ ប៉ុន្តែនីតិវិធីទាំងនេះ មិនអាចប្រានចោលនូវការពិចារណាចំពោះអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ដែលថ្វីមិនត្រូវបានអញ្ជើញមកដាក់តារាងតំលៃ ឬសំណើ តែគេមានបំណងចូលរួមក្នុង កិច្ចការនោះដែរ ។

ជំពូក II

លទ្ធកម្មសេវាទីប្រឹក្សា

មាត្រា ១២ : ការប្រើប្រាស់ទីប្រឹក្សា :

ទីប្រឹក្សាអាចជ្រើសរើសយកមក ដើម្បីផ្តល់នូវសេវាឯកទេស ក្នុងការអនុវត្តន៍គំរោងឬមួយផ្តល់ជំនួយ ឬយោបល់ជំនាញក្នុងការងារពង្រឹងស្ថាប័ន ។ ទីប្រឹក្សាអាចជាក្រុមហ៊ុនទីប្រឹក្សា ឬក៏ជាឯកត្តជន ។

មាត្រា ១៣ : នីតិវិធីជ្រើសរើស :

ក្នុងការជ្រើសរើសទីប្រឹក្សាតាមរយៈការប្រកួតប្រជែងអន្តរជាតិ (ជាទូទៅអនុវត្តបានចំពោះតែក្រុមហ៊ុនផ្តល់ទីប្រឹក្សា) នីតិវិធីមួយចំនួនត្រូវតែអនុវត្តតាម ដូចជាការរៀបចំនូវបញ្ជីរាយនាមសរុប និងបញ្ជីរាយនាមជំរើស នៃទីប្រឹក្សា ការវាយតំលៃសំណើរបស់ទីប្រឹក្សា ការចាត់ថ្នាក់ នៃទីប្រឹក្សា ការជ្រើសរើសទីប្រឹក្សាដែលត្រូវអញ្ជើញ មកធ្វើការចរចា និងចុះហត្ថលេខាលើកិច្ចសន្យា ។ នីតិវិធីទាំងនេះ មានចែងនៅក្នុង IRRPP ។ ចំពោះទីប្រឹក្សាឯកត្តជន នីតិវិធីសាមញ្ញ និងលឿនជាង ពុំតម្រូវអោយដាក់ពាក្យស្នើសុំធំដុំទេ ហើយចំណាត់ថ្នាក់របស់ទីប្រឹក្សាក៏ស្ថិតនៅលើការចេះដឹងផ្ទាល់របស់ឯកត្តជននោះតែប៉ុណ្ណោះ ។

ជំពូក III

នាយកដ្ឋានលទ្ធកម្មសាធារណៈ

មាត្រា ១៤ : ការបង្កើតនាយកដ្ឋានលទ្ធកម្មសាធារណៈ

នាយកដ្ឋានលទ្ធកម្មសាធារណៈ (Department of Public Procurement-DPP) ត្រូវបានបង្កើតឡើង ដើម្បីនឹងបំពេញនាទីជាស្ថាប័នកណ្តាលមួយដើម្បីត្រួតពិនិត្យមើលការខុសត្រូវ និងតាមដានអំពីការប្រតិបត្តិអនុក្រឹត្យនេះ និង IRRPP។ DPP ជានាយកដ្ឋានមួយដែលស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហើយត្រូវបានគ្រប់គ្រងដោយប្រធានម្នាក់ ដែលតែងតាំងឡើងដោយនាយករដ្ឋមន្ត្រីតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៥ : របនាសម្ព័ន្ធអង្គការលេខ :

នាយកដ្ឋានលទ្ធកម្មសាធារណៈ រៀបចំឡើងផ្អែកលើរចនាសម្ព័ន្ធអង្គការលេខអាស្រ័យមុខការ ។ DPP ត្រូវមានបណ្តាផ្នែកប្រតិបត្តិការទៅតាមសេចក្តីត្រូវការជាក់ស្តែងក្នុងនោះត្រូវមានគណៈកម្មាធិការអន្តរក្រសួង សំរាប់ពិនិត្យឡើងវិញចំលងការលទ្ធកម្ម និងអោយសច្ចានុម័ត លើពាក្យសុំចុះបញ្ជី និងបែងចែកប្រភេទ នៃអ្នកទទួលការ ។

មាត្រា ១៦ : ទំហំ នៃការទទួលខុសត្រូវ :

នាយកដ្ឋានលទកម្មសាធារណៈ ត្រូវបំពេញតួនាទីជាអ្នកត្រួតពិនិត្យ លើកិច្ចការលទ្ធកម្មសាធារណៈ នៃបណ្តាក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងស្ថាប័នដែលរដ្ឋកាន់កាប់ ឬស្វ័យគ្រប់គ្រង ។

នាយកដ្ឋានមានភារកិច្ចធ្វើការត្រួតពិនិត្យបច្ចេកទេសជាថ្មីលើចំលងការលទ្ធកម្មដែលទាក់ទិនដល់ចំនួនទឹកប្រាក់ដូចមានចែងក្នុង IRRPP និងត្រូវអោយគេពិគ្រោះ យោបល់នៅពេលណាដែលមានសំនួរលើកឡើងទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្ត វិធាន និងបទបញ្ញត្តិ នៃលទ្ធកម្មសាធារណៈរបស់រាជរដ្ឋាភិបាល ។

នាយកដ្ឋាន និងត្រូវមានអំណាចផងដែរ ក្នុងការអញ្ជើញមន្ត្រីរាជការ ឬបុគ្គលិករដ្ឋណាមួយអោយផ្តល់នូវសេចក្តីបំភ្លឺ ឬដើម្បីឆ្លើយនូវសំនួរផ្សេងៗ ទៅលើទិដ្ឋភាពដែលមានលក្ខណៈពិសេសចំពោះចំលងការលទ្ធកម្ម ។

មាត្រា ១៧ : សិទ្ធិអំណាចរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ :

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិអំណាចក្នុងការរៀបចំ ឬរៀបចំឡើងវិញនូវនាយកដ្ឋានលទ្ធកម្មសាធារណៈ និងកំណត់ ឬកំណត់ឡើងវិញនូវតួនាទីរបស់ផ្នែកប្រតិបត្តិការផ្សេងៗ រៀបចំនីតិវិធី និងនយោបាយប្រតិបត្តិ តាំងតាំងមន្ត្រីរាជការចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានចុះស្របតាមបទបញ្ញត្តិដែលមានមកហើយ និងប្រើសិទ្ធិអំណាចដទៃទៀតដែលយល់ថាជាការចាំបាច់ ដើម្បីធានាការប្រតិបត្តិ និងដំណើរការល្អនៅនាយកដ្ឋាន ។

ជំពូក IV

ការទទួលខុសត្រូវក្នុងកិច្ចប្រតិបត្តិការ

មាត្រា ១៨ : ការទទួលខុសត្រូវរបស់ក្រសួង–ស្ថាប័ន–ខេត្ត–ក្រុង :

ភារកិច្ចទទួលខុសត្រូវ ក្នុងការប្រតិបត្តិនូវអនុក្រឹត្យនេះ ក៏ដូចជា IRRPP ត្រូវកំណត់ដូចតទៅ :

ក_នៅថ្នាក់ក្រសួង ឬស្ថាប័នប្រហាក់ប្រហែល ត្រូវមានអនុរដ្ឋលេខាធិការ ១ រូប ទទួលខុសត្រូវរួមពីលើប្រធាននាយកដ្ឋាននីមួយៗ ដែលមានភារកិច្ចទទួលខុសត្រូវដោយឡែកលើការងារលទ្ធកម្មសាធារណៈ នៅនាយកដ្ឋានរៀងៗខ្លួន ។

ខ_នៅក្នុងស្ថាប័នដែលរដ្ឋកាន់កាប់ ឬស្វ័យគ្រប់គ្រង មន្ត្រីជាន់ខ្ពស់ទីពីរដែលតែងតាំងដោយប្រធានស្ថាប័នជាអ្នកទទួលខុសត្រូវ ។

គ_នៅថ្នាក់ខេត្ត ឬក្រុង អភិបាលខេត្ត ឬអភិបាលក្រុង ជាអ្នកទទួលខុសត្រូវ ។

មាត្រា ១៩ : ដើម្បីជៀសវាងការយឺតយ៉ាវក្នុងចំលងការ នៃលទ្ធកម្មនៅកន្លែងរបស់ខ្លួន មន្ត្រីដែលបានរៀបរាប់ខាងលើ ត្រូវកំណត់និសានវាទ សំរាប់បញ្ចប់យកម្មភាពដោយឡែកណាមួយ ជាពិសេសការវាយតំលៃលើសំណើដេញថ្លៃ ។

[illegible]ងភាពដេញថ្លៃ :

[illegible]ម្បីប្រមូលផ្តុំសកម្មភាពការងារលទ្ធកម្មនៅក្នុងក្រសួង ស្ថាប័ន ខេត្ត–ក្រុង និងស្ថាប័នស្វ័យគ្រប់គ្រង ក្នុងនោះអង្គភាពលទ្ធកម្មមួយត្រូវបានបង្កើតឡើងដើម្បីបំពេញមុខនាទីដូចមានចែងក្នុង IRRPP ។

មាត្រា ២១ : គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃ និងប្រគល់កិច្ចសន្យា (PEAC)

នៅក្នុងក្រសួង ស្ថាប័ន ខេត្ត–ក្រុង និងស្ថាប័នស្វ័យគ្រប់គ្រងនីមួយៗ ត្រូវមាគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតំលៃ និងប្រគល់កិច្ចសន្យា (PEAC) ដែលទទួលខុសត្រូវដឹកនាំផ្នែកបច្ចេកទេស ក្នុងការកំណត់បុរេលក្ខណៈសម្បត្តិ ការដេញថ្លៃ ការវាយតំលៃលើសំណើដេញថ្លៃ និងផ្តល់អនុសាសន៍ប្រគល់កិច្ចសន្យា ។

មាត្រា ២២ : ការត្រួតពិនិត្យចំលងការលទ្ធកម្ម :

គឺជាអង្គភាពនៅក្នុងក្រសួង ស្ថាប័ន ... –ក្រុង ឬស្ថាប័នស្វ័យក្រប់គ្រង ... ការងារត្រួតពិនិត្យគណនេយ្យ ... ការពាក់ព័ន្ធទៅនឹងសកម្មភាព ... ការលទ្ធកម្មក្នុងស្ថាប័ន ។ អង្គភាពនេះត្រូវមានភារកិច្ចត្រួតពិនិត្យលើ ... ការលទ្ធកម្ម ដែលបានបញ្ចប់រួចហើយ ដើម្បីកំណត់បញ្ជាក់ថាតើគេបានធ្វើត្រឹមត្រូវតាមលក្ខខ័ណ្ឌ នៃកិច្ចសន្យាឬយ៉ាងណា ។ អង្គភាពនេះត្រូវធ្វើរបាយការណ៍អំពីគំហើញទាំងឡាយទៅប្រធានស្ថាប័ន និងបញ្ជូនលិខិតចំលង នៃរបាយការណ៍នេះ ទៅនាយកដ្ឋានលទ្ធកម្មសាធារណៈ ដើម្បីជាពត៌មាន និងចាត់ចែងធ្វើសមស្របតាមច្បាប់។

មាត្រា ២៣ : សិទ្ធិអំណាចរបស់គណៈរដ្ឋមន្ត្រី

រាល់កិច្ចសន្យាលទ្ធកម្ម ដែលក្នុងគំរោងនោះមានទាក់ទិនស្រួចស្រាវដល់បញ្ហានយោបាយ ឬមានប៉ះពាល់ខ្លាំងដល់បញ្ហាសង្គម ឬមានឥទ្ធិពលលើបញ្ហាសីលធម៌ ឬក៏ធ្វើអោយខូចដល់បរិដ្ឋាន និងដែលមាន ចំនួនទឹកប្រាក់លើសពី ១.៣០០.០០០.០០០ រៀល ត្រូវតែបញ្ជូនទៅទីស្តីការ គណៈរដ្ឋមន្ត្រីពិនិត្យសំរេចជាចុងក្រោយ តាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំពូក V

ការបែងចែកប្រភេទ និងការចុះបញ្ជី នៃអ្នកទទួលការ

មាត្រា ២៤ : ដើម្បីអោយមានសិទ្ធិចូលរួមក្នុងគំរោងការងារសាធារណៈណាមួយអ្នកទទួលការត្រូវតែទទួលការបែងចែកតាមប្រភេទ និងចាត់ថ្នាក់ដោយយោងទៅតាមប្រភេទនៃ គំរោង ដែលខ្លួនមានសមត្ថភាពនឹងធ្វើបាន ។ ការបែងចែកជាប្រភេទ និងចំណាត់ថ្នាក់ទាំងនេះ ត្រូវធ្វើឡើងដោយគណៈកម្មាធិការអន្តរក្រសួងមួយ ដែលមានសមាសភាពដូចតទៅ :

មន្ត្រីជាន់ខ្ពស់ម្នាក់ នៃនាយកដ្ឋានលទ្ធកម្មសាធារណៈជាប្រធាន តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន និងតំណាងផ្នែក...ក្រុមសំណង់ក្នុងស្រុកជាសមាជិក ។ តំណាងផ្នែកឧស្សាហកម្មសំណង់ក្នុងស្រុក ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រុមបច្ចេកទេសមួយអាចនឹងត្រូវបង្កើតឡើងពីពេលមួយទៅពេលមួយ ដើម្បីធ្វើការវាយតំលៃលើការបែងចែកតាមប្រភេទ និងចំណាត់ថ្នាក់នេះ ។ ... សីក្សាបែងចែក

ប្រភេទ និងការចុះបញ្ជីអ្នកទទួលការ ត្រូវបានរៀបចំឡើងដោយនាយកដ្ឋានលទ្ធកម្មសាធារណៈ ។

ជំពូក VI

នីតិវិធីលទ្ធកម្មសំរាប់គំរោងដែលហិរញ្ញប្បទានដោយបរទេស

មាត្រា ២៥ : កិច្ចសន្យាដែលហិរញ្ញប្បទាន ដោយស្ថាប័នផ្តល់ទុនក្រៅប្រទេស ឬភ្នាក់ងារជំនួយទេ្វភាគី ត្រូវអនុវត្តតាមលក្ខខ័ណ្ឌ នៃកិច្ចព្រមព្រៀងឥណទាន ឬជំនួយរវាងម្ចាស់ទុន ឬអ្នកផ្តល់ជំនួយជាមួយ និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។ ភាគច្រើន នៃកិច្ចព្រមព្រៀងទាំងនេះចែងថា លទ្ធកម្មទំនិញ ឬកិច្ចសន្យាសាងសង់តែងតែប្រព្រឹត្តទៅ ដោយយោងតាមវិធីសាស្រ្ត និងនីតិវិធីដែលចែងដោយស្ថាប័នទាំងនោះដូចមានបញ្ជាក់នៅក្នុងគោល ការណ៍ណែនាំរបស់គេ ឬក៏នៅក្នុងឯកសារកំណត់កាតព្វកិច្ចផ្សេងទៀត ។ ប្រសិនបើមានភាពមិនស៊ីគ្នា ឬមានទំនាស់រវាង IRRPP ជាមួយនឹងវិធីសាស្រ្ត ឬនីតិវិធី នៃស្ថាប័នបរទេសទាំងនោះ វិធីសាស្រ្ត និងនីតិវិធី នៃស្ថាប័នបរទេស នឹងត្រូវយកជាការបាន ។ ប្រសិនបើគ្មានទំនាស់ទាំងនេះទេ អនុក្រឹត្យ និង IRRPP នេះក៏ត្រូវគ្របដណ្តប់ទៅលើកិច្ចសន្យាហិរញ្ញប្បទានបរទេសដែរ ។

ជំពូក VII

ទោសបញ្ញត្តិ

មាត្រា ២៦ : រាល់ទង្វើដែលបង្កអោយមានការរំលោភធ្ងន់ធ្ងរលើអាជ្ញាធរ ឬអំពើមិនគប្បីណាមួយ ឬដែលនាំអោយមានការបំពានលើអនុក្រឹត្យនេះ ឬ IRRPP ដែលប្រព្រឹត្តឡើងដោយមន្ត្រីរាជការ នៃរាជរដ្ឋាភិបាល [illegible]ត្រូវទទួលទណ្ឌកម្មផ្នែក[illegible] ។ ក៏ប៉ុន្តែពុំអាចជៀសផុតពីការ[illegible]ព្រហ្មទណ្ឌ [illegible]នោះផងដែរ ។ ប្រសិនបើរាជរដ្ឋាភិបាល[illegible] ឬខូចខាតដោយសារ[illegible] ឬ[illegible]របស់មន្ត្រីរាជការណាមួយនោះ ជនមានកំហុសនឹងត្រូវសងទូទាត់ការខូចខាត ឬជាតិបង់ទៅតាមសេចក្តីសំរេច របស់តុលាការដែលពាក់ព័ន្ធ ។

មាត្រា ២៧ : រាល់ទង្វើដែលប្រព្រឹត្តឡើងដោយបុគ្គល ឬអង្គការណាមួយ ដែលនាំទៅរកការជួយ ឬការលើកលែងនូវការរំលោភណាមួយលើអនុក្រឹត្យ ឬ IRRPP នេះ និងបណ្ដាលអោយភាគីពាក់ព័ន្ធ ត្រូវបានបញ្ឈប់ទាំងស្រុង ឬជាបណ្ដោះអាសន្នពីការចូលរួមក្នុងចំលងការលទ្ធកម្មសាធារណៈ ។ ក្រៅពីនេះគេនឹងទទួលពិន័យ ឬទណ្ឌកម្មដែលកំណត់ដោយច្បាប់ ។

ជំពូក VIII

អវសានបញ្ញត្តិ

មាត្រា ២៨ : រាល់បទបញ្ញត្តិដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត–ក្រុង ប្រធានស្ថាប័នស្វយ័តគ្រប់គ្រង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦១ អនក្រ.បក

ស្ដីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្ដីពីសភាពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម.០៦៩៥.០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

សំរេច

មាត្រា ១ : បង្កើតសភាពាណិជ្ជកម្មមួយសំរាប់រាជធានីភ្នំពេញ។ព្រំដែនមណ្ឌលសភាពាណិជ្ជកម្មរាជធានីភ្នំពេញនេះ គឺព្រំដែនរាជធានីភ្នំពេញ ។

មាត្រា ២ : សភាពាណិជ្ជកម្មរាជធានីភ្នំពេញ មានសមាជិកជ្រើសតាំងចំនួន ២៤ រូប ដែលជ្រើសរើសតាមការបោះឆ្នោតស្របតាមលក្ខខ័ណ្ឌ ដែលកំណត់ដោយអនុក្រឹត្យមួយដោយឡែកហើយត្រូវបានបែងចែកតាមប្រភេទអាជីវកម្មនិមួយៗ ដូចតទៅ :

១-ប្រភេទពាណិជ្ជកម្ម :....................០៨ រូប
២-ប្រភេទឧស្សាហកម្ម និងសិប្បកម្ម :....................០៨ រូប
៣-ប្រភេទសេវាកម្ម និងវិជ្ជាជីវៈសេរី :....................០៤ រូប
៤-ប្រភេទកសិកម្ម :....................០៤ រូប

មាត្រា ៣ : តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ក្រសួងពាណិជ្ជកម្មត្រូវកំណត់តាមប្រកាសនូវសមាសភាពសមាជិកទីប្រឹក្សា ដែលមានចែងក្នុងមាត្រា ០៥ នៃ ច្បាប់ស្ដីពីសភាពាណិជ្ជកម្ម ។

មាត្រា ៤ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈនៃរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និង ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ

ចាប់ពី ថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦២ អនក្រ.បក

ស្តីពីការគ្រប់គ្រងការប្រើប្រាស់អាវុធ
និង ជាតិផ្ទុះគ្រប់ប្រភេទ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីការផ្តន្ទាទោស ការកាន់អាវុធ និង ការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ១១ ក្រ ចុះ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះ មានគោលដៅបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : ក្រសួងការពារជាតិ មានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រងការប្រើប្រាស់អាវុធ និងជាតិផ្ទុះ ក្នុងកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងជីវពល.

មាត្រា ៣ : ក្រសួងមហាផ្ទៃ មានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រងការប្រើប្រាស់អាវុធ និង ជាតិផ្ទុះ ក្នុងកងកំលាំងនគរបាលជាតិ និង ជនស៊ីវិល ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤ : ជនណាកាន់អាវុធដោយគ្មានការអនុញ្ញាត ត្រូវផ្ដន្ទាទោសតាមមាត្រា ២ មាត្រា ៣ មាត្រា ៤ និង មាត្រា ៥ នៃច្បាប់ស្ដីពីការផ្ដន្ទាទោសការកាន់អាវុធ និង ការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ១១ ក្រ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

ជំពូកទី ២

អំពីសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះ

មាត្រា ៥ : ក្រសួងការពារជាតិ មានសិទ្ធិផ្ដល់លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះចំពោះកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងជីវពល ។

មាត្រា ៦ : ក្រសួងមហាផ្ទៃ មានសិទ្ធិផ្ដល់លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះចំពោះនគរបាលជាតិ និង ជនស៊ីវិល ។

មាត្រា ៧ : លក្ខខ័ណ្ឌនៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និងជាតិផ្ទុះសំរាប់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងជីវពល កងកំលាំងនគរបាលជាតិ និងជនស៊ីវិល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់សហរដ្ឋមន្ត្រីក្រសួង ការពារជាតិ និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ជំពូកទី ៣

សិទ្ធិប្រើប្រាស់អាវុធជាលក្ខណៈបុគ្គល

មាត្រា ៨ : មន្ត្រីរាជការស្ថាប័នស៊ីវិល ដែលអាចអនុញ្ញាតអោយប្រើប្រាស់អាវុធខ្លី ជាលក្ខណៈបុគ្គលបានក្នុងពេលបំពេញបេសកកម្មតាមការកំណត់ថ្នាក់ដូចខាងក្រោម ៖

- នៅក្រសួង ស្ថាប័ន ចាប់ពីថ្នាក់នាយកដ្ឋានឡើងទៅ ។
- នៅខេត្ត ក្រុង រាជធានីភ្នំពេញ ចាប់ពីថ្នាក់អភិបាលរងខេត្ត ក្រុងឡើង

និងចៅ ក្រសួងជុំវិញខេត្ត ក្រុង ។

- នៅខ័ណ្ឌ ស្រុក គឺ អភិបាល និង អភិបាលរង ស្រុក ខ័ណ្ឌ ។ ក្រៅពីបំពេញបេសកកម្ម ត្រូវរក្សាទុកនៅផ្ទះ ។

មាត្រា ៩ : កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង នគរបាលជាតិ អាចអនុញ្ញាតអោយប្រើប្រាស់អាវុធខ្លីជាលក្ខណៈបុគ្គលបាន ក្នុងពេលបំពេញបេសកកម្មតាមការកំណត់ថ្នាក់ដូចខាងក្រោម ÷

- អ្នកមានឋានៈ មុខងារ ចាប់ពីថ្នាក់អនុប្រធានការិយាល័យ និង ថ្នាក់អនុប្រធាន កងអនុសេនាតូចឡើងទៅ ។
- យុទ្ធជន ភ្នាក់ងារ ដែលទទួលបទបញ្ជាអោយទៅបំពេញភារកិច្ចការពារថ្នាក់ដឹកនាំ ឬ អោយទៅបំពេញបេសកកម្មជំនាញនៅតំបន់អសន្តិសុខ ក្រៅពីបំពេញបេសកកម្ម ត្រូវរក្សាទុកនៅផ្ទះ ។

មាត្រា ១០: មន្ត្រីគយ ពន្ធដារ រុក្ខាប្រមាញ់ ជលផល ក្រុមហ៊ុនចំការកៅស៊ូរដ្ឋ បរិដ្ឋាន និង ធនាគារជាតិនៃកម្ពុជា ដែលមានថ្នាក់ដូចមានចែងក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ មានសិទ្ធិប្រើប្រាស់អាវុធខ្លី តែក្នុងពេលចេញទៅបំពេញបេសកកម្ម ។

មាត្រា ១១: ចំពោះអាវុធវែង មិនអនុញ្ញាតអោយប្រើប្រាស់ជាលក្ខណៈបុគ្គលឡើយ ។ អាវុធវែងអាចប្រើប្រាស់តាមអង្គភាព សំរាប់ការពារស្ថាប័ន អង្គភាព ឬ ឃ្លាំង និង សំរាប់ចុះបំពេញបេសកកម្មនៅតាមតំបន់អសន្តិសុខ និង លំនៅដ្ឋាន នៃសមាសជិករាជរដ្ឋាភិបាលសភាជាតិ និងវរជន សំខាន់ឯទៀតដែលរាជរដ្ឋាភិបាលបានសំរេច ។

មាត្រា ១២: ហាមមិនអោយយកកាំភ្លើង វែង ខ្លី ចូលក្នុងរាជធានីភ្នំពេញ ហើយត្រូវទុកនៅប៉ុស្តិ៍គ្រប់គ្រងអាវុធជាតិផ្ទះ តាមការកំណត់ដោយប្រកាសអន្តរក្រសួង របស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

មាត្រា ១៣: បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៤: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ

ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

២_សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៥៣ សសរ

ស្តីពី

ការបង្កើតគណៈកម្មការត្រួតពិនិត្យគោលនយោបាយ

ចំពោះជនពលី—ពិការ

* * * *

រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–ផ្អែកតាមសភាពការណ៍ចាំបាច់ចំពោះមុខ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការត្រួតពិនិត្យគោលនយោបាយចំពោះជនពលីពិការនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

១–ឯកឧត្តម រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ជាប្រធាន

២-ឯកឧត្តម អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី

ជាអនុប្រធាន

៣-ឯកឧត្តម អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ជាអនុប្រធាន

៤-តំណាងក្រសួងការពារជាតិ ជាសមាជិក

៥-តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

៦-លោក [illegible] [illegible] របស់

[illegible] នៃទីស្តីការគណៈរដ្ឋមន្ត្រី

ជាសមាជិក

៧-តំណាងក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

ជាលេខាធិការ

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ៖

-ត្រួតពិនិត្យ និង ធ្វើបញ្ជីស្ថិតិ អំពីចំនួនជនពលីពិការពិតប្រាកដនៅទូទាំង ព្រះរាជាណាចក្រកម្ពុជា ។

-ត្រួតពិនិត្យ និង ធ្វើបញ្ជីស្ថិតិជនពលី ពិការ ដែលបានផ្ទេរសិទ្ធិ ឬ លក់របបរបស់ខ្លួនទៅអោយអ្នកដទៃ ។

-លើកវិធានការទប់ស្កាត់ការលក់ ឬ ផ្ទេរសិទ្ធិក្នុងការបើករបប និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់ គ្រួសារជនពលី ឬ ជនពិការ ។

-រៀបចំប្រព័ន្ធបើករបប និង ប្រាក់ឧបត្ថម្ភជូនគ្រួសារជនពលី ជនពិការអោយបានទាន់ពេលវេលា និង ដល់ដៃសាមីជនបានគ្រប់ចំនួនតាមរបបកំណត់ ។

-ពិនិត្យសំណូមពររបស់ក្រុមគ្រួសារជនពលីពិការនិងលើកវិធានការដោះស្រាយអោយបានសមស្រប ។ ក្នុងករណីជួបការលំបាកត្រូវសុំយោបល់រាជរដ្ឋាភិបាល ។

-ធ្វើទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាលដើម្បីសុំជំនួយគាំទ្រដល់ការអនុវត្តន៍គំរោងការងារនេះ ។

-ផ្សព្វផ្សាយ អំពីពត៌មាននៃលទ្ធផលត្រួតពិនិត្យគោលនយោបាយចំពោះជនពលីពិការជូនសាធារណជន ។

-បូកសរុប និង ធ្វើរបាយការណ៍ អំពីសភាពការណ៍ត្រួតពិនិត្យគោលនយោបាយ

ចំពោះជនពលីពិការ និង ការងារផ្សេងៗទៀតដែលពាក់ព័ន្ធនិងបញ្ហាជនពលី ពិ-ការជូនរាជរដ្ឋាភិបាលអោយបានជាប្រចាំ ។

ប្រការ ៣ : គណៈកម្មការនេះមានទីស្នាក់ការក្នុងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនដើម្បីសំរួលការងារ ។

ប្រការ ៤ : គណៈកម្មការនេះប្រើប្រាស់ថវិកាជួសំរាប់ចំណាយក្នុងការងាររបស់ខ្លួន ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភារកិច្ចដោះស្រាយរាល់ចំណាយដែលបំរើដល់សកម្មភាពរបស់គណៈកម្មការ ។

ប្រការ ៥ : គណៈកម្មការនេះ មានសិទ្ធិបង្កើតក្រុមការងារចំនួន ២៣ ក្រុម សំរាប់ជំនួយការងារក្នុងពេលអនុវត្តជាក់ស្តែងនៅតាមខេត្ត–ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយដែលក្រុមការងារ និមួយៗមានសមាសភាពដូចខាងក្រោម ÷

១–លោកប្រធាន ឬ អនុប្រធាននាយកដ្ឋាននៃក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន	ប្រធាន
២–លោកប្រធាន ឬ អនុប្រធាននាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធាន
៣–លោកប្រធាន ឬ អនុប្រធាននាយកដ្ឋាននៃក្រសួងការពារជាតិ	សមាជិក
៤–លោកប្រធាន ឬអនុប្រធាននាយកដ្ឋាន នៃក្រសួងមហាផ្ទៃ	សមាជិក
៥–លោកប្រធាន ឬអនុប្រធាននាយកដ្ឋាននៃទីស្តីការគណៈរដ្ឋមន្ត្រី	លេខាធិការ

ប្រការ ៦ : ក្រុមការងារទាំង ២៣ ក្រុមនេះមានភារកិច្ច ÷

–ធ្វើជាសេនាធិការអោយគណៈកម្មការដែលមានចែងក្នុងប្រការ ១ ខាងលើក្នុងការចុះត្រួតពិនិត្យ និង រាប់ចំនួនជនពលី ពិការ នៅតាមខេត្ត–ក្រុង ។

–ចូលរួមក្នុងការបើកប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រួសារជនពលី និងជនពិការ នៅពេលចុះបំពេញបេសកកម្មនៅតាមខេត្ត – ក្រុង ។

–ធ្វើការប្រៀបធៀបតារាងបើកប្រាក់ឧបត្ថម្ភប្រចាំខែទៅនឹងចំនួនគ្រួសារជនពលី និង ពិការ ដែលចូលមកបើកប្រាក់នៅតាមខេត្ត–ក្រុង ។

–បូកសរុប និង ធ្វើរបាយការណ៍ជាបន្ទាន់តាមខេត្ត–ក្រុងនិមួយៗ ជូនគណៈកម្មការ ។

-កោះអញ្ជើញក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិគ្រោះពិភាក្សាពីការងារជួសជុល និង អភិវឌ្ឍន៍ព្រលានយន្តហោះទៅខេត្តរតនគិរី

-សិក្សារៀបចំគំរោងប្លង់ព្រមទាំងសំភារៈ ថវិកា ដើម្បីសុំការអនុម័តពីរាជរដ្ឋាភិបាល ធ្វើរបាយការណ៍សុំគោលការណ៍ពីរាជរដ្ឋាភិបាល ក្នុងករណីជួបការលំបាក ក្នុងការស្ថាបនា និង ជួសជុល ។

ប្រការ ៣. គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រាបេះដូងរបស់អាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន [illegible] ។

ប្រការ ៤. [illegible] ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា ប្រធានអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោកដែលមានក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៥៥ សសរ

ស្តីពី

ការបង្កើតលេខាធិការដ្ឋាន នៃក្រុមប្រឹក្សា

ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ «ក ក ជ»

* * * *

ក្រុមប្រឹក្សា « ក.ក.ជ »

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាព នៃរាជរដ្ឋាភិបាល

–បានឃើញច្បាប់ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី [illegible] ឱ្យប្រើដោយ [illegible] ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម [illegible] វរ្ម័ន ព្រះមហាក្សត្រ [illegible] ១៩៩៤

–បានឃើញអនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតក្រុមប្រឹក្សាស្ដារអភិវឌ្ឍវិស័យកសិកម្ម និង ជនបទ

–យោងតាមសំណូមពរការងារចាំបាច់

សម្រេច

ប្រការ ១ . បង្កើតលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាស្ដារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ដែលមានទីតាំងនៅទីស្ដីការគណៈរដ្ឋមន្ត្រី (នាយកដ្ឋានកសិកម្ម) ក្រោមការគ្រប់គ្រងផ្ទាល់របស់ឯកឧត្តម **សុខ អាន** [illegible] លេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី

ប្រការ ២ : សមាសភាពលេខាធិការដ្ឋាននេះ មានដូចខាងក្រោម

១–លោក **សារ៉ាត់ ខាន់** អគ្គលេខាធិការ[illegible] « ក.ក.ជ » ជាប្រធាន

២–លោក **ម៉ៅ គីមសុធារ៉ុ** អនុប្រធានអចិន្ត្រៃយ៍

៣–លោក **សួន សិទ្ធី** អនុប្រធាន

៤–លោក **អ៊ិត ណន្ទី** តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សមាជិក

៥–លោក **ចាប សុវណ្ណ** តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៦–លោក **រ័ត្ន សារុធ** តំណាងធនាគារជាតិកម្ពុជា សមាជិក

៧–លោក **គោះ យ៉ាន**	តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៨–លោក **វ៉ន្ត សៀបគីមសេង**	តំណាងក្រសួងផែនការ	សមាជិក
៩–លោក **សុស គង់**	តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១០–លោក **តូច ចំនួកុសល**	តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន	សមាជិក
១១–លោក **អេង ម៉ុនហួរ**		ជំនួយការ
១២–លោក **សំ ឧត្តរា**		ជំនួយការ
១៣–លោក **ពត ណារិន**		ជំនួយការ
១៤–លោក **ជុំ ម៉ុនហៀង**		ជំនួយការ

ប្រការ ៣ : អនុប្រធានអចិន្ត្រៃយ៍ និង ជំនួយការ នៃលេខាធិការដ្ឋាន ត្រូវប្រចាំការជា អចិន្ត្រៃយ៍នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។ បណ្ដាសមាជិកជាតំណាងក្រសួង ស្ថាប័ននានា ត្រូវទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ក្នុងការសំរេច ភារកិច្ចដែលបានកំណត់ និង ចូលរួមប្រជុំតាមការអញ្ជើញរបស់លេខាធិការដ្ឋាន ។

ប្រការ ៤ : លេខាធិការដ្ឋាន ជាយន្តការជំនួយការអចិន្ត្រៃយ៍ របស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ហើយមានភារកិច្ចដូចខាងក្រោម ÷

–រៀបចំកម្មវិធី និង ខ្លឹមសារសំរាប់អង្គប្រជុំ នៃ « ក.ក.ជ » ដោយសហការជាមួយនាយកដ្ឋាន រដ្ឋបាល និង នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញកិច្ចរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

–ធ្វើលិខិតជូនដំណឹងរបស់ « ក.ក.ជ » និងធ្វើកំណត់ហេតុអង្គប្រជុំរបស់ « ក.ក.ជ » ។

–ពិនិត្យ និង តាមដានការអនុវត្តន៍ការសំរេចរបស់ « ក.ក.ជ » ។

–ធ្វើរបាយការណ៍តាមកាលកំណត់របស់ « ក.ក.ជ » ។

–ជួយសិក្សាស្រាវជ្រាវលើកឡើងនូវវិធានការនានា ដើម្បី «ក.ក.ជ » ពិនិត្យ និង សំរេច ។

–ជាសេនាធិការរបស់ «ក.ក.ជ » ក្នុងការរៀបចំ និង ការប្រព្រឹត្តិទៅ នៃ «ក.ក.ជ » ។

ប្រការ ៥ : រាល់ការចំណាយ និង មធ្យោបាយបំរើការងាររបស់លេខាធិការដ្ឋានស្ថិតនៅ ក្នុង-

បន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦ : ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង សាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវទទួល អនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះ ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

III-ការងារបណ្តាក្រសួង

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីប្រកាសអន្តរក្រសួងលេខ ០២ ប្រ.ក

របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

និង ក្រសួងមហាផ្ទៃ

ស្តីពី

សមត្ថកិច្ចនៃការផ្តល់ទិដ្ឋាការ ចូល—ចេញ និង ស្នាក់នៅ

ព្រះរាជាណាចក្រកម្ពុជា

* * * *

ក្នុងគោលបំណងសំរួលការគ្រប់គ្រង និង ធានាថែរក្សាការពារ សន្តិសុខ និង សុវត្ថិភាពជូនជនបរទេសគ្រប់រូបដែលបានចេញ–ចូល និង ស្នាក់នៅក្នុងព្រះរាជាណាចក្រ កម្ពុជា ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ក្រសួងមហាផ្ទៃ ធ្វើសេចក្តីប្រកាសអន្តរក្រសួងអំពីសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនជនបរទេសដូចតទៅ :

១–ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចេញលិខិតអនុញ្ញាតអោយចូល ក្នុងព្រះរាជាណាចក្រកម្ពុជា ជូនភ្ញៀវបរទេសគ្រប់ប្រភេទ ។

២–ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចផ្តល់ និង ពន្យាទិដ្ឋាការជូនសមាជិកស្ថានទូត ទីភ្នាក់ងារអង្គការសហប្រជាជាតិ តំណាងអង្គការអន្តរជាតិ តំណាងអង្គការក្រៅរដ្ឋាភិបាល គណៈប្រតិភូផ្លូវការ ក្រុមសហប្រតិបត្តិការដែលធ្វើការនៅតាមស្ថាប័ន ក្រសួង មន្ទីរ អង្គភាពរដ្ឋ ជនជាតិខ្មែរជាមន្ត្រីរាជការក្នុងរាជរដ្ឋាភិបាល ព្រមទាំងក្រុមគ្រួសារដែលកាន់លិខិតឆ្លងដែនបរទេសដោយឥតគិតថ្លៃ ។ « ពាក្យក្រុមគ្រួសារដែលប្រើក្នុងសេចក្តីប្រកាសអន្តរក្រសួងនេះ សំដៅលើប្តី–ប្រពន្ធ ឪពុក–ម្តាយ បង្កើត ឪពុក–ម្តាយ ក្មេក កូនបង្កើត–កូនប្រសារ » ។

៣–ស្ថានទូត ស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅបរទេស មានភារកិច្ចផ្តល់ទិដ្ឋាការ លើលិខិតឆ្លងដែនគ្រប់ប្រភេទ ។ ចំពោះទិដ្ឋាការការទូតផ្លូវការសេរីភាព (VISA DE COURTOISIE) ស្ថានទូត និង ស្ថានអគ្គកុងស៊ុលអាចផ្តល់រយៈពេលតាមការស្នើសុំ តែមិន អោយហួសពី ០៦ ខែឡើយ ។ ដោយឡែកចំពោះទិដ្ឋាការធម្មតា ស្ថានទូត និង ស្ថានអគ្គកុងស៊ុល មានសិទ្ធិផ្តល់ទិដ្ឋាការសំរាប់រយៈពេលស្នាក់នៅតែ ០១ ខែទេ ។ ក្នុងករណីពិសេស ឬ មានមន្ទិលសង្ស័យ ត្រូវសុំការអនុញ្ញាតពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។ ស្ថានទូត និង ស្ថានអគ្គកុងស៊ុលត្រូវរាយការណ៍បន្ទាន់ជា ០៣ ច្បាប់អំពីឈ្មោះ សញ្ជាតិ ប្រភេទ និង ចំនួន ទិដ្ឋាការទាំងអស់ដែលបានផ្តល់មកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដើម្បីក្រសួងបញ្ជូនបន្តទៅក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៤–ក្រសួងមហាផ្ទៃ មានភារកិច្ចផ្តល់ទិដ្ឋាការ ០១ ខែ « មួយខែ » ដំបូងនៅព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង ដល់ភ្ញៀវបរទេសទាំងអស់ដែលកាន់លិខិតឆ្លងដែនគ្រប់ប្រភេទក្នុងករណីដែលគេពុំបានយកទិដ្ឋាការពីស្ថានទូត ឬ ស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅបរទេស ។

៥–ក្រសួងមហាផ្ទៃ មានភារកិច្ចពន្យាការស្នាក់នៅជូនជនបរទេសដែល កាន់លិខិតឆ្លងដែនធម្មតា ហើយជនបរទេសនោះមិនស្ថិតក្នុងប្រភេទដែលជាសមត្ថកិច្ចរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

៦–ក្រសួងមហាផ្ទៃ ត្រូវផ្តល់ពត៌មានអំពីឈ្មោះ សញ្ជាតិ ចំនួន និង ប្រភេទទិដ្ឋាការរបស់ភ្ញៀវទាំងអស់ ដែលបានចូលព្រះរាជាណាចក្រកម្ពុជា តាមគ្រប់ច្រកទ្វារព្រំដែន ជូនក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៧–តំណាងក្រសួងមហាផ្ទៃ អមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) មានសិទ្ធិពន្យាទិដ្ឋាការជូនវិនិយោគិនទាំងអស់ ដោយអនុវត្តតាមច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ។

៨–ចំពោះលិខិតធ្វើដំណើរ (TITRE DE VOYAGE) របស់ពលរដ្ឋកម្ពុជានៅបរទេស ដែលពុំទាន់មានសញ្ជាតិបរទេស ត្រូវផ្តល់ទិដ្ឋាការអណ្តែត ។ សមត្ថកិច្ចត្រួតពិនិត្យពុំត្រូវវាយត្រាចូល- ចេញលើលិខិតធ្វើដំណើរនេះទេ ។

៩–ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចេញប័ណ្ណស្នាក់នៅជូនជនបរទេសទាំងអស់ដែលបានទទួលទិដ្ឋាការការទូត ផ្លូវការ សេរីភាព (VISA DE COURTOISIE) និង ទិដ្ឋាការមិនយកថ្លៃ ។

សេចក្តីប្រកាសអន្តរក្រសួងនេះ ចាប់អនុវត្តពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
ស ខេង **យូ ហុកគ្រី**	**អ៊ុង ហួត**

២_ទីស្តីការរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៤១៩ សសរ.កសក

ស្តីពីការតែងតាំងគណៈកម្មការដេញថ្លៃ

ជីគីមី ក្នុងក្របខ័ណ្ឌថវិកាជំនួយជី FAO

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ ១០៩៤ នស.រកត ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញលិខិតលេខ ៩២២ សជណ.កស ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការអនុញ្ញាតជាគោលការណ៍ប្រើប្រាស់ថវិកាដែលបានមកពីជំនួយជី FAO ដើម្បីនាំចូលសំភារៈកសិកម្ម

សំរេច

ប្រការ១ : តែងតាំងគណៈកម្មការមួយដើម្បីរៀបចំការងារវេញថ្លៃនាំចូលជីតីមីក្នុងក្របខ័ណ្ឌថវិកា ដែលបាន មកពីជំនួយជី FAO ដែលមានសមាសភាពដូចតទៅ :

១-លោក **ស៊ិន នីនី**	ប្រធានមន្ទីរក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ប្រធាន
២-លោក **លួន គិមឆោ**	ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ	អនុប្រធាន
៣-លោក **គិត សេខ**	អនុប្រធាននាយកដ្ឋានផែនការស្ថិតិ	សមាជិក
៤-លោក **ជ័យ សានឧទ្ស**	ប្រធានក្រុមហ៊ុនសំភារៈកសិកម្ម	សមាជិក
៥-លោក **ញ៉ឹម ចំនួនថេត**	ប្រធានការិយាល័យហិរញ្ញកិច្ច ន.គណនេយ្យ ហិរញ្ញវត្ថុ	សមាជិក

របស់ប្រធាននាយកដ្ឋានបច្ចេកទេស សេដ្ឋកិច្ច និងផ្សព្វផ្សាយ ។

ប្រការ ៥: កម្មវិធីផលិតកម្មស្បៀងជាលក្ខណៈគ្រួសារ «ផ.ស.គ» របស់ក្រសួង ការិយាល័យ អប់រំ និង ផ្សព្វផ្សាយបច្ចេកទេសកសិកម្មចំណុះមន្ទីរភិនក្រសួង ត្រូវផ្ទេរចូលក្នុង បន្ទុកនាយកដ្ឋានបច្ចេកទេស សេដ្ឋកិច្ច និង ផ្សព្វផ្សាយ ។

ប្រការ ៦ : សេចក្តីសំរេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ លេខ ០០១៧ កសក. សសរ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងគណៈប្រតិបត្តិកម្មវិធី ផលិតកម្មស្បៀងជាលក្ខណៈគ្រួសារ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានគណនេយ្យ–ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ–ស្ថិតិ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានបច្ចេកទេស សេដ្ឋកិច្ច និងផ្សព្វផ្សាយ ប្រធានមន្ទីរកសិកម្មគ្រប់ខេត្ត–ក្រុង និង ប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
តាវ សេងហួរ

* * *

គំនូសតាងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន
បច្ចេកទេស សេដ្ឋកិច្ច និងផ្សព្វផ្សាយ



ភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា និងត្រា
តាវ សេងហួរ

៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៥៣៦ ឧក.ប្រក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ជាង សំអាត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៧២៦០ ភ.ព ចុះថ្ងៃទី ០៤-១១-៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះសង់ថ្មី ផ្លូវលេខ ២៦១ ក្រុមទី ២២ សង្កាត់ទឹកល្អក់ទី ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បើកដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ជាង សំអាត** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ គិតចាប់ពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាង ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល ព្រមទាំងគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន។

ប្រការ ៤ : រោងជាងនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្ត : សាឡុងឈើ តុ ទូ រូបចម្លាក់ផ្សេងៗ និង ជួសជុល តុ-ទូ-សាឡុង ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់រោងជាង ត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មផលិតកម្មរបស់រោងជាង ផ្ញើ

មកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាង ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៥៣៧ ឧក.ប្រក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអោយសិប្បកម្មកែច្នៃផ្តៅ ដែលមានលោក **លី អេងហុង** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៧៥៥៩ ភ.ព ចុះថ្ងៃទី ១៧–៣–៩៤ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១០៣ អឺ១ហ្សៃត ផ្លូវលេខ ២១៧ ក្រុមទី ៣៣ សង្កាត់អូឬស្សីទី ៣ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើរការ សិប្បកម្មកែច្នៃផ្តៅ នៅក្នុងទីតាំងភូមិក្រាំងជូនទៃ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **លី អេងហុង** ត្រូវរៀបចំដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូច បានកំណត់ក្នុងប្លង់ ក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខា លើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះ ត្រូវទុកជាមោឃៈ ។

ប្រការ ៣ : ក្នុងពេលដំណើរការផលិតកម្មម្ចាស់ត្រូវធានាសុវត្ថិភាពឧស្សាហកម្មធានាបរិដ្ឋាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិ ដែលមាន ជាធរមាន ។

ប្រការ ៤ : ម្ចាស់សិប្បកម្ម ត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ អំពីកាលបរិច្ឆេទនៃការចាប់ដំណើរការជាផ្លូវការ និងធ្វើរបាយការណ៍ ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់សិប្បកម្ម ។

ប្រការ ៥ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណី ប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវ ដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៤០ ផក.ប្រក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

ស្ដីពីការដកហូតរោងចក្រឡឥដ្ឋ ជ្រោយអំពិល

ស្ថិតនៅផ្លូវជាតិលេខ ១ ឃុំក្បាលកោះ ស្រុកកៀនស្វាយ

ខេត្តកណ្ដាល

រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា

– បានឃើញលិខិតលេខ ០៩ របា.៩៥ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥ របស់គណៈកម្មាធិការត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងចំណារថ្នាក់ដឹកនាំ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥

– បានឃើញកិច្ចសន្យាជួលរោងចក្រ ចុះថ្ងៃទី ២៦–៦–១៩៩១ របស់លោក **គី ទីន**

សំរេច

ប្រការ ១ : ដកហូតរោងចក្រឡឥដ្ឋជ្រោយអំពិល ស្ថិតនៅផ្លូវជាតិលេខ ១ ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាលពីលោក **គី ទីន** ដោយមូលហេតុមិនគោរពកិច្ចសន្យាក្នុងការជួលអង្គភាពនេះ ។

ប្រការ ២ : លោក **គី ទីន** ដែលជាអតិថិជន ជួលរោងចក្រឡឥដ្ឋជ្រោយអំពិលនេះ ត្រូវទូទាត់ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នូវថ្លៃសម្ភារៈ និង ថ្លៃឈ្នួលរោងចក្រអោយបានគ្រប់ចំនួន ដូចក្នុងលិខិតលេខ ០៩ របា.៩៥ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : សេចក្ដីសំរេចលេខ ៨១៥ ចត.សសរ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩១ របស់ក្រសួងឧស្សាហកម្ម ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : លោកប្រធាននាយកដ្ឋានផែនការ លោកប្រធាននាយកដ្ឋានគណនេយ្យ លោកប្រធាននាយកដ្ឋានបច្ចេកទេស លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធានគណៈកម្មាធិការត្រួតពិនិត្យ និងសាមីអតិថិជន លោក **គី ទីន** ត្រូវអនុវត្តប្រកាសតាមសមត្ថកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ិត ប្រាំង

ប្រកាសលេខ ៥៤១ ឧក. ប្រក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ឃិន គង់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៣១៦៨៦ ភ.ព ចុះថ្ងៃទី ០៤–៧–៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣០ ផ្លូវ ២៤០ ក្រុមទី ១៨ សង្កាត់ទីកល្អក់ទី ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មផលិតផលឆ្នាំង និង ខ្ទះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៥៤២ ឧក. ប្រក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយមានអ្នកស្រី **ខែម ណារត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩៤១០៧ ក.ណ ចុះថ្ងៃទី ០១–៦–៨៧ អាស័យដ្ឋានបច្ចុប្បន្នភូមិក្តីចាស់ ឃុំចាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល បន្តដំណើរការឡផលិតឥដ្ឋ–ក្បឿង នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៥៤៣ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **យង់ ស្រួយ** ជាម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដែលមានទីតាំងនៅផ្ទះលេខ ១០ ក្រុមទី ១ ភូមិសំណាញ់ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក **ចាន់ ណៃ** វិញ ។

ប្រការ ២ : ទទួលស្គាល់លោក **ចាន់ ណៃ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៦៦៧០០ ប.ប ចុះថ្ងៃទី ០៩–៧–៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៤ ក្រុមទី ៥ ភូមិភ្នំសំពៅលិច ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ជាម្ចាស់រោង ម៉ាស៊ីនកិនស្រូវ ។

ប្រការ ៣ : លោក **ចាន់ ណៃ** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ ឬ បង្កអោយមានការខូចខាតដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៥៤៤ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **អេង ស៊្រុន** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៨៨៧៨ ភ.ព ចុះ ថ្ងៃទី ០៦–៦–៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៣២អឺ១ ផ្លូវលេខ ១៤៣ ក្រុមទី ៨៤ សង្កាត់វាលវង់ ខ័ណ្ឌ ៧ មករា-រាជធានីភ្នំពេញ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ នៅក្នុងទីតាំងភូមិព្រែកតាកែ ឃុំបឹងធំ ស្រុកភ្នំពេញ ខេត្តកណ្តាល ។

ប្រការ ២ : លោក **អេង ស៊្រុន** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៥៤៥ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **លាង ឡី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណបណ្ណលេខ ០០៨៧៥៣ប.ប ចុះថ្ងៃទី ០៧-១២-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១១ក្រុមទី ១៧ ភូមិទួលតាឯក សង្កាត់ស្វាយប៉ោ ២ ទីរួមខេត្តបាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការសិប្បកម្មផលិតទឹកត្រីពិសេសយីហោ «**អៀងឡី**» នៅក្នុងទីតាំងក្រុមទី ១ ភូមិអូរចារ សង្កាត់សាមគ្គី ទីរួមខេត្តបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **លាង ឡី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកត្រីពិសេស សញ្ញា «**រូបកូនក្មេង**» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ិត ប្រាំង

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៥១ មស.ប្រក

ស្តីពីការផ្ទេរមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញលិខិតលេខ ២៨១ ស.ហវ.ប ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការសុំអនុញ្ញាតផ្ទេរក្របខ័ណ្ឌលោក **លុយ ម៉ុនហុង** នាយករងក្រុមហ៊ុនវាយនភ័ណ្ឌ ខេត្តកំពង់ចាម អោយមកជាអនុប្រធានទី ១ នៃមន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តកំពង់ចាម ។

សំរេច

ប្រការ ១ : ផ្ទេរក្របខ័ណ្ឌ ១ កន្លែង ឥណទានបៀវត្ស និង លោក **លុយ ម៉ុនហុង** នាយករងក្រុមហ៊ុនវាយនភ័ណ្ឌខេត្តកំពង់ចាម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជូនទៅ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាស្ថាពរ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីជន ត្រូវបានទទួលនៅអង្គភាពថ្មី ដោយគិតពីថ្ងៃដែលបានផ្តាច់ពីអង្គភាពចាស់ ។

ប្រការ ៣ : លោកនាយកខុទ្ទកាល័យ ប្រធាន[illegible]នាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញកិច្ច ក្រុមហ៊ុនវា[illegible]ណ្ឌខេត្តកំពង់ចាម និង លោក **លុយ ម៉ុនហុង** មានភារកិច្ចអនុវត្តក្នុងក្រ[illegible]សមត្ថកិច្ចរៀងៗ ខ្លួន តាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធ[illegible]អនុវត្តចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ិត ប្រាំង

៤_នីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៥៧/៩៥ ពម.ប្រក

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មាន លេខ ១.២២៤.៩៤ព.ម ចុះថ្ងៃទី ១៤-១១-១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ «**ពន្លឺពេជ្រ**» របស់លោក **តាំង សុភាព** ចុះថ្ងៃទី ០២ ខែ ៧ ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **តាំង សុភាព** ស្ថិតនៅផ្ទះលេខ ៨៧ អឺ.០ ផ្លូវ លេខ ៦៣ ក្រុម៣៨ សង្កាត់ បឹងរាំង ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « **ពន្លឺពេជ្រ** » ស្ថិតនៅលំនៅខាងលើ ។

ប្រការ២: រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របទៅនឹងទំនៀមទំលាប់ សន្តិសុខ-សណ្តាប់ធ្នាប់ សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា

ប្រការ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួន នឹង ត្រូវទទួល ទោស-តាមច្បាប់ជាធរមាន ។

ប្រការ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ-សោតទស្សន៍ នៃ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពពតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

[illegible]

ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៥៨/៩៥ ពម.ប្រក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាជំពូកអវសានប្បញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័ត នាសម័យប្រជុំ វិសាមញ្ញ ថ្ងៃ ទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតស្នើសុំអនុញ្ញាតបោះពុម្ពផ្សាយសារពត៌ឈ្មោះ « **ខ្មែរអង្គរ** » ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់លោក **សាយ យាន**

សំរេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មានឈ្មោះ « **ខ្មែរអង្គរ** » ចេញផ្សាយដោយមានលោក **សាយ យាន** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមច្បាប់សារពត៌មាន គោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួននិងស្នើប្រគល់កាសែត ចំនួន ១៥ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅ ក្រសួងពត៌មាន ។

ប្រការ ៤ : លោក **សាយ យាន** ចាងហ្វាងសារពត៌មាន «ខ្មែរអង្គរ» និងនាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មានត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ : ១៥៩/៩៥ ពម.សសរ

ស្តីពីការបង្កើតគណៈកម្មការសាងសង់

- បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- ពិនិត្យលើសំណូមពរ និង ភារកិច្ចរបស់ក្រសួង
- ពិនិត្យលើសមត្ថភាព របស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយសំរាប់ទទួលបន្ទុកសាងសង់ ផ្ទះមុខងារនៅក្រសួងពត៌មាន រួមមានសមាសភាពដូចខាងក្រោមនេះ ÷

១-	ឯកឧត្តម	**អ៊ុំ នាស៊ាម**	ប្រធាន
២-	លោក	**សាន សំបូរ**	អនុប្រធាន
៣-	លោក	**ថែន សំណាង**	សមាជិក
៤-	លោក	**សេង ម៉ាលីស**	–
៥-	លោក	**ហ៊ុន ផល្លុន**	–
៦-	លោក	**រស់ ប៊ុនធុល**	–
៧-	លោក	**សេង ឌីន**	–
៨-	លោក	**ឡើង សម្បត្តិ**	–
៩-	លោក	**ផុស សុវណ្ណ**	–

ប្រការ ២ : គណៈកម្មការសាងសង់នេះមានភារកិច្ច ÷

- លើកគំរោងសាងសង់អោយបានច្បាស់លាស់-ធ្វើការដេញថ្លៃតាមគោលការណ៍រដ្ឋ
- មែងចែកភារកិច្ចទទួលខុសត្រូវនិងគិតគូរស្នើសុំថវិកា
- គិតគូរមញ្ជីចំណាយសមស្របតាមលក្ខការណ៍
- បូកសរុបនិងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

ប្រការ ៣ : អគ្គនាយកដ្ឋាន រដ្ឋបាល ហិរញ្ញវត្ថុ អគ្គាធិការដ្ឋាននិងសាមីខ្លួន មានភារកិច្ច អនុវត្ត

នូវសេចក្តីសំរេចអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៦០/៩៥ ពម.ប្រក

ស្តីពី ការតែងតាំងមន្ត្រីរាជការបណ្តោះអាសន្ន

* * * * *

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តមសីហនុ វរ្ម័ន** ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- យោងអនុក្រឹត្យលេខ ៥៩ អនក្រ ចុះថ្ងៃទី ០៧ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្តូរបទនាសម្ព័ន្ធរដ្ឋបាលក្រុងកែបពីថ្នាក់ស្រុកមកថ្នាក់ក្រុង
- ពិនិត្យលើសំណើសុំតែងតាំងរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង កែប លេខ ០៧ សណ.ក្រក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥
- ពិនិត្យលើសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១: តែងតាំងជាបណ្តោះអាសន្ននូវមន្ត្រីរាជការដូចមានរាយនាមខាងក្រោមនេះជាថ្នាក់ដឹកនាំមន្ទីរពត៌មាន ក្រុងកែប ÷

១- លោក **អ៊ុក សាខន** បច្ចុប្បន្នជាអនុប្រធានការិយាល័យពត៌មានក្រុងកែបទៅជាប្រធានមន្ទីរពត៌មានបណ្តោះអាសន្នប្រចាំក្រុងកែប

២- លោក **ម៉ម ឈឿន** បច្ចុប្បន្នជាវរសេនីយ៍ទោកងវិស្វកម្មក្រសួងការពារជាតិ ទៅជាអនុប្រធានមន្ទីរពត៌មានបណ្តោះអាសន្នប្រចាំក្រុងកែប

៣– លោក **ខ៊ែត គួន** បច្ចុប្បន្នជាអនុប្រធានផ្នែករដ្ឋបាលការិយាល័យពតិមានទៅជាអនុប្រធានមន្ទីរពតិមានបណ្តោះអាសន្នប្រចាំក្រុងកែប

ប្រការ ១ : នាយកខុទកាល័យ អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរពតិមានក្រុងកែបនិងសាមីខ្លួនមានភារៈអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៦១/៩៥ ពម.ប្រក

ស្តីពី ការលុបឈ្មោះ មន្ត្រី រាជការ

* * * *

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មិនា ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

– ពិនិត្យលើសំណើបញ្ជូន លេខ ៤៣១ ពមរ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់មន្ទីរពតិមានរាជធានីភ្នំពេញ

– ពិនិត្យលើសំណើសុំឈប់បំរើការងាររបស់សាមីខ្លួន

សំរេច

ប្រការ ១ : លុបឈ្មោះ អ្នកស្រី **ស៊ុម ដារី** ជាបុគ្គលិក នៃមន្ទីរពតិមានរាជធានីភ្នំពេញ ចាប់ពីថ្ងៃ ០១ ខែ កញ្ញា ១៩៩៥ នេះតទៅ ដោយសាមីខ្លួនស្ម័គ្រចិត្តសុំឈប់ បំរើការងារ។

ប្រការ ២ : អ្នកស្រី **ស៊ុម ដារី** ដូចបានចែងក្នុងប្រការ ១ ត្រូវទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើ :

២៩.៩៦០៖ គុណ ១០ : ២៩៩.៦០០៖០០ « ពីររយកៅសិបប្រាំបួនពាន់ ប្រាំមួយរយ រៀលគត់ » ។

ប្រការ ៣ : អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរពត៌មាន រាជធានីភ្នំពេញ និង សាមីខ្លួនមានភារៈអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ០២៣/៩៥ ពម.ប្រក

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការមន្ត្រីរាជការ

* * * * *

– បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តមសីហនុ** វរ្ម័ន ចុះ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– ពិនិត្យលើការយល់ព្រមរបស់អគ្គនាយកដ្ឋានវិទ្យុជាតិចុះថ្ងៃទី១៣–៧–១៩៩៥
– ពិនិត្យលើសំណើសុំផ្លាស់ប្តូរកន្លែងធ្វើការរបស់សាមីខ្លួន

សំរេច

ប្រការ ១ : យល់ព្រមជូនលោក **រស់ រតនា** មន្ត្រីនៅអគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា អោយមក បំរើការងារនៅនាយកដ្ឋានមណ្ឌលពត៌មាន នៃទីស្តីការរដ្ឋមន្ត្រី ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន អគ្គនាយកដ្ឋាន វិទ្យុជាតិ កម្ពុជា ត្រូវផ្ទេរមកទីស្តីការរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : នាយកដ្ឋាន មណ្ឌលសារពត៌មាន ត្រូវរៀបចំសំរួលបែងចែកភារកិច្ចជូនលោក **រស់ រតនា** អោយបានសមស្របតាមសមត្ថភាព ។

ប្រការ ៤ : អគ្គនាយកដ្ឋាន វិទ្យុជាតិ , នាយកដ្ឋាន បុគ្គលិក និង រដ្ឋបាល , នាយកដ្ឋាន ផែនការ គណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋាន មណ្ឌលសារពត៌មាន និង សាមីខ្លួន

មានភារៈ អនុវត្តតាមប្រកាសចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

រាជធានីភ្នំពេញ ; ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៦៤/៩៥ ពម.ប្រក

ស្ដីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌស្ងួន

* * * * * *

- បានឃើញ ព្រះរាជក្រឹត្យស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យ ស្ដីពីការតែលំអរបៀវត្សកម្មាភិបាល បុគ្គលិក កម្មករ រដ្ឋ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩២
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានវិទ្យុជាតិ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៥
- ពិនិត្យលើសំណូមពររបស់សាមីខ្លួន

សំរេច

ប្រការ ១ : លុបឈ្មោះលោក **សុខ ចាន់ថន** អនុប្រធានការិយាល័យគ្រប់គ្រង ដែលបានចូលបំរើការងារពីថ្ងៃទី ០១-០១-១៩៨០ ចេញពីក្របខ័ណ្ឌ អគ្គ នាយកដ្ឋានវិទ្យុជាតិ នៃក្រសួងពត៌មាន ចាប់ពីថ្ងៃទី ០១-១០-១៩៩៥ តទៅ

ប្រការ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវបានទទួលម្ដងគត់ ស្មើប្រាក់បៀវត្សសរុបក្នុង ១ ខែ គុណ ចំនួនឆ្នាំបានបំរើការងារដែលមានដូចខាងក្រោមនេះ ÷

លោក **សុខ ចាន់ថន** : ៤៣.៦៨០៛ គុណ ១០ : ៤៣៦.៨០០៛០០

ប្រការ ៣ : អគ្គនាយកដ្ឋាន វិទ្យុជាតិ នាយកដ្ឋាន រដ្ឋបាល បុគ្គលិក នាយកដ្ឋាន គណនេយ្យ

ផែនការ ហិរញ្ញកិច្ច និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

៥_ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៣៣ ប្រក.វវស.មុ

ស្តីពី

ការបង្កើតគណៈកម្មការ សិក្សាស្រាវជ្រាវ វិស័យបេតិកភណ្ឌវប្បធម៌

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីត្រូវការចាំបាច់របស់ក្រសួង

សំរេច

មាត្រា ១ : ត្រូវបានបង្កើត គណៈកម្មការមួយ សំរាប់ចុះទៅ សិក្សាស្រាវជ្រាវ វិស័យបេតិកភណ្ឌ វប្បធម៌នៅស្រុក អង្គរបុរី ចាប់ពីថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥ រហូតដល់ចប់ការងារ។

មាត្រា ២ : សមាសភាពគណៈកម្មការនេះរួមមាន ÷

១– លោក ជុច ឆឿន	ប្រធាននាយកដ្ឋាន បេតិកភណ្ឌវប្បធមិ	ប្រធាន
២– លោក ឡុយ ឆឿន	ប្រតិភូប្រចាំសាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ	អនុប្រធាន
៣– លោក អ៊ុក ខា	ទីប្រឹក្សារដ្ឋមន្ត្រី	សមាជិក
៤– លោក អ៊ុក ស៊ុនហេង	ប្រធានការិយាល័យ បច្ចេកទេស នាយកដ្ឋានបេតិកភណ្ឌវប្បធមិ	សមាជិក
៥– លោក ប្រាក់ អ៊ិច	ប្រធានមន្ទីរ វប្បធមិ និង វិចិត្រសិល្បៈ ខេត្តតំណាងអភិបាលខេត្តតាកែវ	សមាជិក
៦– លោក ឈុន ស្រ៊ី	ស្រុកអង្គរបុរី	សមាជិក
៧– លោក ខា សេន	ប្រធានឃុំ ព្រៃកផ្ទោល	សមាជិក
៨– លោក ជូ ផាវិន	ប្រធានឃុំ អង្គរបុរី	សមាជិក
៩– លោក អ៊ុម ឈិត	ប្រធានឃុំ គោកធ្លក	សមាជិក

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស និង សាមីជន មានភារកិច្ចអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
នុត ណារ៉ាង

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៣៥ ប្រក.វវស.ប្រ

ស្តីពីការបង្កើតគណៈកម្មការមហាប្រយោគ ប្រឡងជ្រើសរើស
សិស្ស និស្សិត ចូលរៀន ឆ្នាំសិក្សា ១៩៩៥–៩៦

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

– បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម-សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– តាមសំណើរបស់ សាកលវិទ្យាល័យ ភូមិន្ទ វិចិត្រសិល្បៈ

សំរេច

មាត្រា ១ : ត្រូវបានបង្កើតគណៈកម្មការមេប្រយោគ សំរាប់ការប្រឡងជ្រើសរើស សិស្ស និស្សិតចូលរៀនក្នុងឆ្នាំសិក្សា ១៩៩៥–៩៦ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ និងថ្ងៃបន្តបន្ទាប់។

មាត្រា ២ : សមាសភាពគណៈកម្មការមេប្រយោគមានដូចតទៅ ÷

១– អ្នកអគ្គម្ចាស់ **ស៊ីសុវត្ថិ ស៊ីរីវុធ ម៉ាណារ៉ា** រដ្ឋលេខាធិការ ប្រធាន

២– លោក **នុយ គឿន** ប្រតិភូទទួលខុសត្រូវ សាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ អនុប្រធាន

៣– លោក **ឡោ សាន** សាកលវិទ្យាធិការរង សមាជិក

៤– លោក **អ៊ុក សុជាតិ** អនុប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

៥– លោក **ស៊ោ ឡៀង** ព្រឹទ្ធបុរសមហាវិទ្យាល័យ សូនរូប សមាជិក

៦– លោក **ឡឿន ឈាង** ព្រឹទ្ធបុរសមហាវិទ្យាល័យ សិល្បៈនាដសាស្ត្រ សមាជិក

៧– លោក **ខ៊ែន ផាត** ព្រឹទ្ធបុរសមហាវិទ្យាល័យ តូរ្យតន្ត្រី សមាជិក

៨– លោក **ចាប ស៊ួន** ប្រធានការិយាល័យ អប់រំ សិក្សា សមាជិក

មាត្រា ៣ : គណៈកម្មការមេប្រយោគ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬ ក្រុមទាំងឡាយ

ដែលជាតម្រូវការចាំបាច់ ក្នុងដំណើរការប្រឡង ។

មាត្រា៤: ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេសសាកល វិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់ចប់ភារកិច្ច ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាង

ಙಜ

ಙಜ❀ಙಜ

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ:១៣៦ ប្រក.វវស.បុ

ស្តីពី

ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

=========

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតលេខ ២៤៧-៩៥ វវលស ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ អគ្គនាយកដ្ឋានព្រះបរមរាជវាំង

សំរេច

មាត្រា ១ :មន្ត្រីរាជការចំនួន០៥ដូចមានខាងក្រោមនេះបច្ចុប្បន្នបុគ្គលិកនាយកដ្ឋានបេតិកភ័ណ្ឌវប្បធម៌ ត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅអគ្គនាយកដ្ឋានព្រះបរមរាជវាំង ៖

១- លោក ពេញ ហេង

២- លោក អ៊ុក សារឿន

៣- លោក ជឹម ធឿន

៤- លោក នាង សុផា

៥- លោក ជឹម សុជាតិ

មាត្រា ២ : ក្រសួងនឹងផ្ទេរប្រាក់បៀវត្ស និង របបឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន ព្រមទាំង ក្របខ័ណ្ឌ ០៥ កន្លែងជូនអគ្គនាយកដ្ឋាន ព្រះបរមរាជវាំង ។

មាត្រា ៣ : ខុទ្ទកាល័យអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋាន បេតិកភ័ណ្ឌវប្បធម៌ ព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
នុត ណារ៉ាង

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៣៧ ប្រក.វវ.ស.មុ

ស្តីពី

ការបង្កើតគណៈកម្មការពិនិត្យ និង វាយតំលៃរបាយការណ៍ បញ្ចប់កម្មសិក្សារបស់និស្សិតឆ្នាំទី ៥ ជំនាន់ទី១ នៃមហាវិទ្យាល័យ ស្ថាបត្យកម្ម និង នគរោបនីយវិទ្យា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

======

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

– តាមសេចក្តីត្រូវការជាចាំបាច់របស់ក្រសួង

សំរេច

មាត្រា ១ : ត្រូវបានបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យ និង វាយតំលៃរបាយការណ៍បញ្ចប់ កម្មសិក្សា របស់និស្សិត ឆ្នាំទី ៥ ជំនាន់ទី១ នៃមហាវិទ្យាល័យស្ថាបត្យកម្ម និង នគរោបនីយវិទ្យាសាកល វិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

មាត្រា ២ : សមាសភាព នៃគណៈកម្មការ មានសមាសភាពដូចតទៅ ÷

១– ឯកឧត្តម	**នុត ណារ៉ាង**	ប្រធាន
២– លោក	**ឌុយ គឿន**	ប្រតិភូទទួលខុសត្រូវសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អនុប្រធាន
៣– លោក	**គឿង សោភ័ណ្ឌ**	ព្រឹទ្ធបុរសមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យា អនុប្រធាន
៤– ឯកឧត្តម	**គ្រីយ៉ មិង ហុង**	សមាជិក
៥– លោក	**យន យ៉យ**	លេខាធិការ

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមុីខ្លួន ត្រូវអនុវត្តភារកិច្ចតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
នុត ណារ៉ាង

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៣៨ ប្រកវវស.ប្រ

ស្តីពី

ការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ
មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត បន្ទាយមានជ័យ

=========

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំផ្លាស់ប្តូរកន្លែងធ្វើការរបស់លោក **ទ៉ាន់ ដារ៉ាន់** បុគ្គលិក នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តបន្ទាយមានជ័យទៅបំរើការងារនៅសាលាខេត្តបន្ទាយមានជ័យ ចុះថ្ងៃ ទី ០១ ខែ ឧសភា ឆ្នាំ ១៩៩៥
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៩៥ ។
- យោងតាមចំណារយល់ព្រមពីឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី ២៧ ខែ មិថុនា និងថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

សំរេច

មាត្រា ១ : លោក **ទ៉ាន់ ដារ៉ាន់** បុគ្គលិកការិយាល័យរដ្ឋបាល ផែនការ និង ហិរញ្ញកិច្ច នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារ នៅសាលាខេត្តបន្ទាយមានជ័យ ។

មាត្រា ២ : មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ត្រូវផ្ទេរប្រាក់បៀវត្សរបប ឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន និង ក្របខ័ណ្ឌមួយកន្លែងជូនសាលាខេត្តបន្ទាយមានជ័យ ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបន្ទាយមានជ័យ ព្រមទាំងលោក **ទ៉ាន់ ដារ៉ាន់** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាង

ភ្នំពេញ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ: ១៣៩ ប្រក.វវស.ប្ក

ស្តីពី

ការលុបឈ្មោះមន្ត្រីរាជការ

=========

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញពាក្យសុំលាឈប់ពីការងាររបស់សាមីខ្លួន

សំរេច

មាត្រា ១ : លោក **ម៉េង សាវុធ** បុគ្គលិកសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌបុគ្គលិកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ ដោយសុំលាឈប់ ។

មាត្រា ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ និង សាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាង

ភ្នំពេញ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ: ១៤០ ប្រក.វវស.ប្ក

ស្តីពី

ការផ្អាកការងារមួយរយៈដោយពុំទទួលបៀវត្ស

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសារាចរណែនាំលេខ ០៣ សរ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៩៣ ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការស៊ីវិលផ្អាកការងារមួយរយៈដោយគ្មានបៀវត្សប្រចាំខែ
- យោងតាមសំណើសុំរបស់លោក **ទ្រែង ទុន្នី** បុគ្គលិកនៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តបាត់ដំបង ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយឈប់សំរាកផ្អាកការងារចំនួន ០១ ឆ្នាំ ដល់លោក **ទ្រែង ទុន្នី** បុគ្គលិក នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបាត់ដំបង ដោយគ្មានបៀវត្ស និង ស្នើសុំរក្សា ទុកក្របខ័ណ្ឌដដែល ដោយគិតចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ០១ ខែសីហា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : បៀវត្សប្រចាំខែ និង រាល់ផលប្រយោជន៍របស់ លោក **ទ្រែង ទុន្នី** ត្រូវផ្អាកលែងអោយបើក ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ តទៅរហូតដល់មានលិខិតអនុញ្ញាតអោយចូលបំរើការ ងារពីក្រសួងវិញ ។

មាត្រា ៣ : នាយកដ្ឋានបុគ្គលិក និងកិច្ចការសង្គម នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញវត្ថុ មន្ទីរ វប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបាត់ដំបង ព្រមទាំងលោក **ទ្រែង ទុន្នី** ត្រូវអនុវត្តនូវប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និងត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ចិណណារ៉ា

ភ្នំពេញ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ: ១៤១ ប្រក.ទវស.មុ

ស្តីពី

ការផ្អាកការងារមួយរយៈដោយពុំទទួលបៀវត្ស

=========

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសារាចរលេខ ០៣ សរ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៩៣ ស្តីពីការ អនុញ្ញាតអោយមន្ត្រីរាជការស៊ីវិលផ្អាកការងារមួយរយៈដោយគ្មានបៀវត្ស ប្រចាំខែ
- យោងតាមសំណើសុំរបស់លោក **រិទ្ធ សេរីត** បុគ្គលិកនៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត បាត់ដំបង ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៩៥
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយឈប់សំរាកផ្អាកការងារចំនួន ០១ ឆ្នាំ ដល់លោក **រិទ្ធ សេរីត** បុគ្គលិក នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបាត់ដំបង ដោយគ្មានបៀវត្ស និង ស្នើសុំ រក្សាទុកក្របខ័ណ្ឌដដែល ដោយគិតចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : បៀវត្សប្រចាំខែ និង រាល់ផលប្រយោជន៍របស់ លោក **រិទ្ធ សេរីត** ត្រូវផ្អាកលែងអោយបើក ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ តទៅរហូតដល់មានលិខិតអនុញ្ញាតអោយចូលបំរើការងារពីក្រសួងវិញ ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបាត់

ដំបង ព្រមទាំង លោក រិទ្ធ សារិត ត្រូវអនុវត្តនូវប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាង

ភ្នំពេញ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ: ១៤២ ប្រក.វចស.ម

ស្តីពី

ការលុបឈ្មោះមន្ត្រីរាជការ មន្ទីរវប្បធម៌ និង

វិចិត្រសិល្បៈខេត្តបាត់ដំបង

=========

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំលុបឈ្មោះ លេខ ៣៣១ វធខ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តបាត់ដំបង
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : មន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តបាត់ដំបងចំនួន ០២ (ពីរ) នាក់ ដូចមានរាយនាមខាងក្រោមនេះ ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌ មន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបាត់ដំបងចាប់ ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៩៥ ដោយបោះបង់ចោលការងារ ÷

១- លោក **ម្លូយ គុលស** បុគ្គលិកការិយាល័យសិល្បៈ

២- លោក **ហ៊ឹម ការ៉ន** បុគ្គលិកការិយាល័យវប្បធម៌ស្រុក ស្វាយចេក

មាត្រា ២ : នាយកដ្ឋានបុគ្គលិក និង កិច្ចការសង្គម នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញវត្ថុ មន្ទីរ វប្បធម៌ និង វិចិត្រសិល្បៈខេត្តបាត់ដំបង ព្រមទាំងសាម៉ីខ្លួនមាន ភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាង

៦_ទីស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៣១៥ សកប

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសំណូមពរការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : តែងតាំង និង តម្លើងឋានៈ លោក វេជ្ជ ប **ម៉េងចូ** បច្ចុប្បន្នប្រធានការិយាល័យ ស្ថិតិ និង ផែនការអោយទទួលជាអនុប្រធាននាយកដ្ឋានសុខាភិបាល ។

ប្រការ ២ : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ប្រការ ៣ : ខុទ្ទកាល័យក្រសួងសុខាភិបាល នាយកដ្ឋានសុខាភិបាល និង លោកវេជ្ជប **ម៉េងចូ**

ត្រូវទទួលភារកិច្ចអនុវត្តតាមប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ទេជ្ជ ឈា ម៉ាំង

៧_ទីស្តីការក្រសួងធម្មការ និងសាសនា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៥៤/៩៥ កធស.ប្រក

ស្តីពីការទទួលស្គាល់មន្ត្រីរាជការ

ក្នុងក្របខ័ណ្ឌ ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៥
- បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីធម្មការ និង សាសនា ដែល ប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និងសាសនា
- បានឃើញប្រកាសលេខ ០៤៩ សហវ.ប្រក.ប ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សំរេច

ប្រការ ១ : ទទួលស្គាល់លោក **ទិញ យ៉េន** អនុប្រធានការិយាល័យ នៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តបាត់ដំបង ត្រូវផ្ទេរអោយទៅធ្វើការនៅមន្ទីរធម្មការ និង សាសនា ខេត្តបាត់ដំបង ។

ប្រការ ២ : បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេង ៗ របស់លោក **ទិញ យ៉េន** អាស្រ័យដោយ

មន្ទីរធម្មការ និង សាសនាខេត្តជាអ្នកទទួលចាត់ចែង និង រ៉ាប់រង ។

ប្រការ ៣ : មន្ទីរធម្មការ និង សាសនាខេត្តបាត់ដំបង លោក **ទិញ យ៉េន** ត្រូវអនុវត្ត តាមប្រកាសនេះ រៀង ៗ ខ្លួន ។

ប្រការ ៤ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខា និងត្រា

ហឿន វណ្ណារ័ត្ន

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៩/៩៥ កធស

ស្តីពីការបែងចែកភារកិច្ចជូនដល់រដ្ឋលេខាធិការ

និង អនុរដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា និងទីស្តីការ

* * *

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំង ឯកឧត្តម **ហឿន វណ្ណារ័ត្ន** ជារដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៅតាមក្រសួងស្ថាប័ន និង រដ្ឋលេខាធិការដ្ឋាន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការ រដ្ឋមន្ត្រីក្រសួងធម្មការ ដែលប្រកាសអោយ ប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងធម្មការ
- សំណូមពរការងារចាំបាច់របស់ក្រសួង

សំរេច

មាត្រា ១ : ឯកឧត្តម **ហឿន វណ្ណារ័ត្ន** រដ្ឋលេខាធិការ ជាប្រធានស្ថាប័នមានភារកិច្ចដឹកនាំ

មាតិនយោបាយសាសនារបស់រាជរដ្ឋាភិបាល ទទួលខុសត្រូវចំពោះសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងចំពោះរដ្ឋសភាជាតិ ក្នុងការដឹកនាំក្រសួង ។

ក្នុងតួនាទីនេះ រដ្ឋលេខាធិការទទួលបន្ថែមនូវការងារខុទ្ទកាល័យ នាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច នឹងទំនាក់ទំនងក្នុងនិងក្រៅប្រទេស «ជាតិនិង អន្តរជាតិ» ។

ប្រការ ២ : ឯកឧត្តមអនុរដ្ឋលេខាធិការ ជាអ្នកជំនួយការផ្ទាល់ និងជាសហការីជិតស្និទ្ធបំផុតរបស់រដ្ឋលេខាធិការក្នុងកិច្ចសហការគ្នាដឹកនាំក្រសួងអោយបានរីកចំរើន ។ អនុ រដ្ឋលេខាធិការត្រូវបានប្រគល់ភារកិច្ចអោយសម្របសម្រួលការងាររបស់ នាយក ដ្ឋានជំនាញមួយ ។ ហើយរាយការណ៍ពីសកម្មភាពរបស់នាយកដ្ឋានទាំងនោះជូនរដ្ឋលេខាធិការ ដោយជៀសវាងចូលជ្រៅក្នុងការងារផ្ទៃក្នុងរបស់នាយកដ្ឋានជំនាញ ។

១-ឯកឧត្តម **ឈន.សឿម** អនុរដ្ឋលេខាធិការទទួលបន្ទុកសម្របសម្រួលការងារ ពុទ្ធសាសនាបណ្ឌិត្យ ។

២-ឯកឧត្តម **អ៊ីស្មាឯល ខូស្មាន** អនុរដ្ឋលេខាធិការទទួលបន្ទុកសម្របសម្រួលការងារនាយកដ្ឋានសាសនា ។

៣-ឯកឧត្តម **ដោក ណារិន** អនុរដ្ឋលេខាធិការទទួលបន្ទុកសម្របសម្រួលការងារអគ្គាធិការពុទ្ធិកសិក្សា ។

ប្រការ ៣ : លោក **ឃី ឆន់** ទីប្រឹក្សាក្រសួងធម្មការ និងសាសនា ជាអ្នកជំនាញការ និងជាអ្នកជំនួយការផ្ទាល់របស់រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ត្រូវទទួលភារកិច្ចដែលរដ្ឋលេខាធិការ ប្រគល់ជូនផ្ទាល់ ។

ប្រការ ៤ : ពេលអវត្តមានរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការមួយរូប ដែលទទួលការផ្ទេរសិទ្ធិមានសិទ្ធិចុះហត្ថលេខាលើលិខិតស្នាមផ្សេងៗ ជាផ្លូវការរបស់ក្រសួង ។

ប្រការ ៥ : ឯកឧត្តមដូចមានរាយនាមក្នុងប្រការ ២ និង ៣ នាយកខុទ្ទកាល័យ និងប្រធាននាយកដ្ឋានទាំងអស់ នៃក្រសួងត្រូវទទួលបន្ទុក និងអនុវត្តប្រកាសនេះតាមសមត្ថកិច្ច និងភារកិច្ចរៀងៗ ខ្លួន ។

ប្រការ ៦ : រាល់សេចក្តីសំរេច ដែលពាក់ព័ន្ធនឹងការបែងចែកភារកិច្ចនេះ ដែលមានពីមុនចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : សេចក្តីប្រកាសនេះមានអនុភាពគតិយុត្តិពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

ហត្ថលេខា និងត្រា

ហ៊ឿន ចន្ទរ័ត្ន

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៦០/៩៥ កធស.ប្រក

ស្តីពីការទទួលស្គាល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួង ធម្មការ និង សាសនា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំង រាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា
- បានឃើញប្រកាសលេខ ៣០២ ប្រក ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រសួងមហាផ្ទៃ

សំរេច

ប្រការ ១ : ទទួលស្គាល់ ពុធ ខួច មន្ត្រីសាលាខេត្តតាកែវ ត្រូវផ្ទេរអោយទៅធ្វើការនៅមន្ទីរធម្មការ និង សាសនាខេត្តតាកែវ ។

ប្រការ ២ : តែងតាំងលោក **ពុធ ខួច** ជាប្រធានមន្ទីរធម្មការ និងសាសនា ខេត្តតាកែវ ។

ប្រការ ៣ : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេង ៗ របស់លោក **ពុធ ខួច** អាស្រ័យដោយមន្ទីរ ធម្មការ និងសាសនាខេត្ត ជាអ្នកទទួលចាត់ចែង និង រ៉ាប់រង ។

ប្រការ ៤ : មន្ទីរធម្មការ និងសាសនាខេត្តតាកែវលោក **ពុធ ខួច** ត្រូវអនុវត្តតាមប្រកាស

នេះរៀង ៗ ខ្លួន ។

ប្រការ ៥ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

ហត្ថលេខា និងត្រា

ហឿន វណ្ណារិត្ត

៨_និស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៣១៤ ប្រក. បស្ថ

ស្តីពីការផ្ទេរភារកិច្ច មន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស. រកត ១០-៩៤-៨៣ ចុះថ្ងៃទី ២៤-១០-៩៤
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញការឯកភាព ចុះថ្ងៃទី ០១ ខែ ៧ ឆ្នាំ ១៩៩៥ របស់ក្រសួងសុខាភិបាល

សំរេច

ប្រការ ១ : ផ្ទេរភារកិច្ចជូនលោក **គួច ម៉ុនគោ** និងក្របខ័ណ្ឌមួយកន្លែង បច្ចុប្បន្នបំរើការងារនៅអាគារធិការដ្ឋាន អោយទៅបំរើការនៅក្រសួងសុខាភិបាល ។

ប្រការ ២ : ប្រាក់បៀវត្ស និងរបបឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន ក្រសួងសុខាភិបាលជាអ្នកផ្តត់ផ្គង់បន្តបន្ទាប់ពីមានវិញ្ញាបនប័ត្រផ្តាច់ប្រាក់ពីអង្គភាពដើម ។

ប្រការ ៣ : អគ្គនាយក ខុទ្ទកាល័យ គ្រប់អង្គភាពដែលពាក់ព័ន្ធ និងលោក **កួច ម៉ិនតោ** ត្រូវទទួលបន្ទុកអនុវត្តន៍ ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៣៤៩ ប្រក.បស្ថ

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងសំនើរបស់មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តកំពត លេខ ៦៨-៦៩ បស្ថកព ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៥
- ពិនិត្យលើការចាំបាច់របស់មន្ទីរគ្រប់គ្រងបរិដ្ឋាន ខេត្តកំពត

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការថ្នាក់ការិយាល័យចំណុះអោយមន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តកំពត ដូចមានរាយឈ្មោះខាងក្រោម :

-លោក **សំ សុន**	ជាប្រធានការិយាល័យរដ្ឋបាល បុគ្គលិក និង ហិរញ្ញកិច្ច
-លោក **អ៊ុក ចាន់ឌីណា**	ជាប្រធានគណនេយ្យ

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេង ៗ ត្រូវបានកែសម្រួលតាមតួនាទី ភារកិច្ចថ្មីរបស់ខ្លួន ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយក មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្តកំពត អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

៩_រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៥២៨ សសរ.មស.ក្រខ

ស្តីពីការបែងចែកសិស្ស និស្សិត ចំនួន ០៦ នាក់

ដែលទើបបញ្ចប់ការសិក្សា ក្រៅប្រទេស

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តមសីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១២៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៣១៩ សជណ.ផក ចុះថ្ងៃទី ២៨-០២-៩៥

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រចំនួន ០១ នាក់ អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៣ នាក់ និងអ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០២ នាក់ ដែលបានបញ្ចប់ការសិក្សា ពីក្រៅប្រទេសត្រូវបានបែងចែកអោយទៅបំរើការងារនៅតាមក្រសួងមួយចំនួនដូចមានក្នុងតារាងឧបសម្ព័ន្ធ នៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួងដែលពាក់ព័ន្ធមានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនសាមីជនចាប់ពីថ្ងៃដែលគេបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ប្រាក់ សុខ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

តារាងឧបសម្ព័ន្ធ នៃ សេចក្តីសំរេចលេខ ៥២៨ សសរ.មស.ប្រក
ចុះថ្ងៃទី ២៧ ខែ ៧ ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកសិស្ស និស្សិត
ចំនួន ០៦ នាក់ ដែលទើបបញ្ចប់ការសិក្សានៅក្រៅប្រទេស

* * *

ល.រ	នាមត្រកូល និងនាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំកំណើត	អង្គភាពដើម	មុខជំនាញបច្ចេកទេស	បៀវត្ស	ប្រភពបណ្តុះបណ្តាល
		១- <u>ទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០១ នាក់</u> :					
		ក—អ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០១ នាក់					
១	អ៊ូ ម៉ូនីកា	ប	២២-៦-៧០	សិស្ស	ផែនទី	៩០.ឱ.១	១
		<u>២—ក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ០១ នាក់</u>					
		ក—អ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០១ នាក់					
២	អ៊ួរ យាង	ប	១៥-៨-៦៤	សិស្ស	បច្ចេកទេស	៩០.ឱ.១	២

សំណង់រថភ្លើង

៣—ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ចំនួន ០១ នាក់

ក—អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ ចំនួន ០១ នាក់

៣ យ៉ង សាំងកុមារ ប ១៨–៧–៦៦ សិស្ស សេ.កិ កសិកម្ម ៩០.៣ ៤ ២

៤—ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០១ នាក់

ក—អ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០១ នាក់

៤ ទេព រូជា ស្រី ២០–១០–៦៦ បុគ្គ.ក្រុមហ៊ុន អគ្គិសនីកម្ពុជា សេ.កិផែនការនិងសង្គម ៣.១ ១

៥—ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ចំនួន ០១ នាក់

ក—អ្នកបច្ចេកទេសថ្នាក់មធ្យម ចំនួន ០១ នាក់

៥ ហ៊ុយ សៀង ប ១០–៧–៦៧ សិស្ស ផលិតអំបោះ ៩០.៣.១ ១

៦—ក្រសួងសុខាភិបាល ចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់មធ្យម ចំនួន ០១ នាក់

៦ វង្ស នារី ស្រី ១០–០១–៦៨ សិស្ស ធ្មប ៩០.៣.១ ៣

បានបញ្ចប់បញ្ជីត្រឹមចំនួន ០៦ នាក់ «ប្រាំមួយនាក់» ប៉ុណ្ណោះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឡោក់ សុខ

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១១៧៦ រៀល